Free

សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា

KhmerPost USA

E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

មាតិការរឿង Issue 217 from. Jan. 20th - Feb. 02th, 2017

**មានរូបប្រធានាធិបតីទាំងអស់នៅទំព័រកណ្ដាល**

១-លោក អ៊ុង វិទ្ធី ប្រធានថ្មីរបស់គណបក្ស............០៤
២-សាលាក្រុងបានតម្លើងពន្ធផ្ទះដោយគ្មាន.............០៦
៣-លោក ម៉ាយរ វាល ប្រកាសពីការពង្រីក..........០៨
៤-ទស្សនាព្រះសក្យមុនិចេតិយនៅលើ.................១៥
៥-លោក ស ខេង យល់ស្របតាមរបាយការ..........១៦
៦-រឿងប្រលោមលោក "ចៅពិន".......................២៣

**Office:** Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A Lowell, MA 01852

# ពិធីសម្ពោធ ឌណាល ត្រាម ជាប្រធានាធិបតីអាមេរិកាំង និងព្យុហយាត្រាស្ត្រីពិភពលោក

## Donald Trump's Inauguration & Women's March

**ដោយ ពិន សំខុន**

ថ្ងៃសុក្រទី២០មករាឆ្នាំ២០១៧ ជាថ្ងៃដ៏នក្ខត្តឫកសម្រាប់លោក ឌណាល ត្រម ដែលបន្ទាប់ពីបានប្រយុទ្ធក្នុងការឃោសនាយ៉ាងស្វិតស្វាញអស់រយៈពេលជិត២ឆ្នាំមក ក៏ទទួលបានមកដល់ការកាន់តំណែងដ៏កំពូលបង្អស់ គឺប្រធានាធិបតីនៅសហរដ្ឋអាមេរិក នឹងជាកំពូលបង្អស់សម្រាប់ពិភពលោកផងដែរ ដោយសារសហរដ្ឋអាមេរិកជាប្រទេសដែលនាំមុខពិភពលោកនឹងនាំមុខវិស័យអាវកាសផង។ ចូលរួមដោយប្រធានាធិបតីមុនផងចំនួន៤ គឺលោកប្រធានាធិបតី "ជីមី ការទ័រ" លោកប្រធានាធិបតី "ប៊ីល គ្លីងតុន" **តទៅទំព័រទី ០៣**




ពិធីសច្ចាប្រណិធានប្រធានាធិបតី ដណាល ត្រម និងលោក ម៉ាយ ផែន

ការិយាល័យមេធាវី លុយ ហាស្កែល
Attorney Louis S. Haskell
បង្កើនកំរិតប្រាក់ពន្ធរបស់អ្នកឱ្យបានជាអតិបរមា
Income Tax Preparation
- មេធាវីដែលមានបទពិសោធន៍ជាច្រើនទសវត្សរ៍
- ទទួលបានប្រាក់ចំណូលពន្ធ និងការបង្វិលប្រាក់ពន្ធបានឆាប់រហ័ស
- បើកបំរើសេវាពេញមួយឆ្នាំ ដើម្បីជាទួយការពារលោកអ្នក
- ស្វាគមន៍ដោយមិនចាំបាច់មានការណាត់ជួបជាមុន
- មិនចាំបាច់រង់ចាំ
- តម្លៃសេវាទាប
- ATTORNEY WITH DECADES OF EXPERIENCE
- SPEEDY TAX RETURNS AND REFUNDS
- OPEN YEAR ROUND TO PROTECT YOU
- WALK-INS WELCOME
- NO WAITING
- LOW FEES
OPEN 7 DAYS A WEEK DURING TAX SEASON



16 PINE ST. LOWELL, MA 978-459-8359

ការិយាល័យ មេធាវី ថូមាស ស្តាលីយ៉ាណូស
Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852
- Immigration • អន្តោប្រវេសន៍
- Auto Crash • គ្រោះថ្នាក់រថយន្ត
- Divorce • លែងលះប្តីប្រពន្ធ
សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766

CENTURY PHARMACY & OPTICAL
937 Gorham St ALL MAJOR INSURANCES ACCEPTED Tel: 978-455-6554
ឱសថស្ថានសេនជូរី : យើងជាអ្នកបំរើលោកអ្នកយ៉ាងប្រសើរ!




- ផ្តល់សេវាដល់ទីលំនៅ
- ខ្ចប់ឱសថតាមបំណង
- ជាឱសថស្ថានដែលលោកអ្នកអាចជឿជាក់ក្នុងចិត្ត
937 Gorham St Lowell, MA, 01852
លេខទូរស័ព្ទ 978-455-6554 / លេខហ្វាក់ 978-455-9476

I DO TAXES



Law Office of Thomas Stylianos
978-459-5000
មានបទពិសោធន៍២៥ឆ្នាំ
យើងបម្រើធ្វើតាក់សម្រាប់លោកអ្នក
ការិយាល័យយើងខ្ញុំ បើកទាំងពេលយប់ និងចុងសប្តាហ៍(រដូវធ្វើតាក់)
287 Appleton Street. Lowell MA 01852



ដោយសារតែ

**Health Connector**

មនុស្សរាប់ពាន់នាក់ស្វែងរកផែនការធានារ៉ាប់រងសុខភាពសំបូរបែបក្នុងតម្លៃទាប ឬឥតគិតថ្លៃ។

# អ្នកមានការធានា!

MASSACHUSETTS HEALTH CONNECTOR

យើងខ្ញុំភ្ជាប់ទំនាក់ទំនងលោកអ្នកទៅនឹងការថែទាំសុខភាពរបស់អ្នក!

ការចុះឈ្មោះបើកទូលាយនឹងបញ្ចប់ថ្ងៃទី៣១ ខែមករា
ហើយគឺជាពេលវេលាប្រចាំឆ្នាំដែលត្រូវទទួលការធានារ៉ាប់រងសុខភាព ឬទិញផែនការថ្មីមួយសម្រាប់ឆ្នាំបន្ទាប់

## ការធានារ៉ាប់រងដែលមានគុណភាពខ្ពស់

ផែនការសុខភាពរបស់ Health Connector ទាំងអស់រ៉ាប់រងលើអត្ថប្រយោជន៍សំខាន់ៗ ដែលរួមមាន៖

- ការជួបពិនិត្យជាមួយវេជ្ជបណ្ឌិត
- សេវាសង្គ្រោះបន្ទាន់
- ការចូលសំរាកព្យាបាលនៅមន្ទីរពេទ្យ
- ការប្រើប្រាស់ឱសថតាមវេជ្ជបញ្ជា
- ការថែទាំពេលមានផ្ទៃពោះនិងទារកទើបនឹងកើត
- សេវាស្តារនិតិសម្បទាឡើងវិញ
- ការព្យាបាលបង្ការនឹងសុខមាលភាព
- ការធ្វើតេសនៅមន្ទីរពិសោធន៍
- សុខភាពផ្លូវចិត្ត និងការប្រើប្រាស់គ្រឿងញៀន

## ត្រូវការជំនួយក្នុងការចុះឈ្មោះ?

សូមទៅកាន់មជ្ឈមណ្ឌលក្នុងតំបន់របស់អ្នក៖

**Boston**
133 Portland Street
Boston, MA 02114

**Lowell**
161 Jackson Street
Lowell, MA 01852

ចូលមើល **www.MAhealthconnector.org** ឬទូរស័ព្ទទៅលេខ **1-877-623-6765 | TTY 1-877-623-7773**

តមកទំព័រទី 0១

# ពិធីសម្ពោធលោក ឌុណល ត្រម...

លោកប្រធានាធិបតី "ជច ឌឺបិលយូ ប៊ូស" នឹងលោកប្រធានាធិបតី "បារ៉ាក់ អូបាម៉ា", លោក "ឌុណល ត្រម" បានធ្វើសច្ចាប្រណិធាននៅចំពោះមុខប្រជាជាតិចូលកាន់ដំណែងជាប្រធានាធិបតីនៃសហរដ្ឋអាមេរិក, បន្ទាប់មកមានសច្ចាប្រណិធាននៃលោក"ម៉ាយ ផែន" ចូលកាន់ដំណែងជាអនុប្រធានាធិបតី ។ "ហ៊ីឡារី គ្លីង តុន" ជាបេក្ខជនអភ័ព្វនឹងជាអតីតស្ត្រីទី១ជាមួយ "ប៊ីល គ្លីងតុន" ក៏មានវត្តមានផ្លូវការក្នុងពិធីផ្ទេរដំណែងប្រកបដោយសន្តិភាពនេះដែរ ។ តែនៅពីក្រៅទីលាន"វិមានកាពីតូល" ឯណោះ ក៏មានបាតុកររាល់ម៉ឺននាក់ ក៏មកបង្ហាញខ្លួនយ៉ាងកុះករបង្ហាញពីការមិនពេញចិត្តនឹងការឡើងកាន់ដំណែងប្រធានាទីបតីរបស់"ឌុណល ត្រម" ដោយសម្លេងតិចជាងគូរប្រជែងរបស់ខ្លួន "ហ៊ីឡារី គ្លីង តុន" ហើយនឹងការមិនពេញចិត្តចំពោះទស្សនៈនៃប្រធានាធិបតីថ្មីចំពោះស្ត្រីចំពោះអ្នកកាន់សាសនាមូស្លីម ...ហើយបាតុកម្មនោះសន្យានឹងនៅបន្តយូរទៅទៀត នឹងកាន់តែធំទៅអនាគត ។

**តើ"ឌុណល ត្រម"ជានរណា?**

ឌុណល ត្រម Donald Trump ឡើងមកធ្វើសច្ចាប្រណិធាន នៅ "វិមានកាពីតូល" ចំពោះមុខសភានឹងចំពោះមុខប្រជាជាតិ ដើម្បីទទួលគោរមងារជាប្រធានាធិបតីទី៤៥នៃសហរដ្ឋអាមេរិក



ចូលកាន់កាប់សេដ្ឋវិមានជំនួសលោកប្រធានាធិបតី បារ៉ាក់ អូបាម៉ា ដែលទើបនឹងបញ្ចប់២អាណត្តិ



គ្រួសារលោក ដណល ត្រម នៅជួរមុខនាឱកាសសច្ចាប្រណិធាននៅមុខកាពីតូលហៀល

ដែលមាន៨ឆ្នាំរបស់លោកមក។ ជាមួយគ្នានោះភរិយារបស់លោក គឺ មីឡែញ៉ា ត្រម ក៏ទទួលបានគោរមងារជាស្ត្រីទី១នៃសហរដ្ឋអាមេរិក ហើយលោក ម៉ាយ ផែន ក៏បានទទួលដំណែងជាអនុ-ប្រធានាធិបតីនៃសហរដ្ឋអាមេរិកដែរ ។

កើតនៅថ្ងៃទី១៤មិថុនាឆ្នាំ១៩៤៦ លោក ឌុណល ត្រម នៅទីក្រុងញូយ៉ក ក្នុងគ្រួសារជាពាណិជ្ជករខាងអចលនវត្ថុ ។ លោកបានរៀនចប់នៅមហាវិទ្យាល័យ"វ៉ថុន"នៅផែនស៊ីវេនា ឆ្នាំ ១៩៦៨ ។ លោកបានបន្តកាន់ការងារពាណិជ្ជកម្មគ្រួសារខាងអចលនវត្ថុដែលមានឈ្មោះថា "អេលីស្ហាបេត ត្រម នឹង បុត្រ"នោះនៅឆ្នាំ១៩៧១ ក្រោយមកប្តូរឈ្មោះជា"អង្គការ ត្រម - The Trump Organization"។ ក្នុងអង្គការនោះ ត្រមបានសានសង់"បិលឌីង"ខ្ពស់ៗ, សណ្ឋាគារ, "កាស៊ីណូ", ទីលានវាយកូនគោលជាច្រើន, ថែមទាំងជាម្ចាស់នៃអង្គការ"បវរកញ្ញាសហរដ្ឋអាមេរិក" នឹងអង្គការ "បវរកញ្ញាពិភពលោក" ពីឆ្នាំ១៩៩៦ ដល់ ២០១៥, ព្រមទាំងលក់ឈ្មោះលើ"ផលិផលប្រណិត"ជាច្រើនផង។ ពីឆ្នាំ២០០៤-១៥ ត្រមដឹកនាំការបង្រៀនការលក់ដូរអចលនវត្ថុ តាមទូរទស្សន៍ "អិនប៊ីស៊ី"ទៀត, ដែលទាំងអស់នោះបានធ្វើឱ្យអង្គការ "ហ្វ៊ បេស"កំណត់ត្រមថា ជាមនុស្សមានសម្បត្តិច្រើនទី៣២៤លើពិភពលោកនឹងទី១១៣ក្នុងសហរដ្ឋអាមេរិក ដោយសារមានសម្បត្តិ $៤,៥ ប៊ីលីយ៉ុង។



ក្នុងឆាកនយោបាយ ត្រម បានចូលប្រឡូកក្នុង"គណបក្សកែទម្រង់ - Reform Party" នៅឆ្នាំ២000 តែបានដកខ្លួនចេញមកវិលនៅមុនពេលបោះឆ្នោត។ ឆ្នាំ២០១២ទៅចូល "គណបក្សសាធារណរដ្ឋ-Republican Party" ដើម្បីឈរឈ្មោះជាបេក្ខជនប្រធានាធិបតីតែបានដកខ្លួនចេញទៅវិញ, ប៉ុន្តែត្រឡប់មកឈរឈ្មោះម្តងទៀតនាឆ្នាំ២០១៥នេះសម្រាប់ការបោះឆ្នោតឆ្នាំ២០១៦, មិនយូរប៉ុន្មាន ត្រម បានឈ្នះអ្នកដែលចូលមកប្រកួតគ្នាក្នុងចំណោមបេក្ខជនគណបក្សសាធារណរដ្ឋទាំងអស់ចំនួន១៧រូប ដែលមកឃោសនានៅជុំទីមួយ ការប្រកួតបានបញ្ចប់នៅខែឧសភា ២០១៦ ដោយមានការតែងតាំងជាបេក្ខជនគណបក្សសាធារណរដ្ឋជាផ្លូវការក្នុងបហាសន្និបាតខែកក្កដា ២០១៦, ពេលនោះលោក ម៉ាយ ផែន ក៏បានទទួលការតែងតាំងជាមួយគ្នា ក្នុងតួនាទី "បេក្ខជនអនុប្រធានាធិបតី"។ ការឃោសនារបស់ ត្រម នឹង ផែន បានទទួលនូវការផ្សព្វផ្សាយខ្លាំងក្លាមិនដែលធ្លាប់មានពីប្រព័ន្ធ"ម៉េឌីយ៉ា" នឹងសហគមន៍អន្តរជាតិ, ប្រយោគនឹងបទសម្ភាសន៍ជាច្រើនរបស់ ឌុណល ត្រម នៅប្រព័ន្ធ"ម៉េឌីយ៉ា"សង្គមនឹងនៅដង្ហែក្បួនឃោសនាបានបង្កើតជា"បញ្ហាឬក៏មិនពិត"។

ត្រមបានឈ្នះការបោះឆ្នោតថ្ងៃទី ៨ វិច្ឆិកា ២០១៦ ប្រកួតនឹងគូប្រជែងលោកស្រី ហ៊ីឡារី គ្លីងតុន មកពីគណបក្សប្រជាធិបតេយ្យ ។ ក្នុងអាយុ៧0ឆ្នាំ លោកក៏បានក្លាយជា "ប្រធានាធិបតីដែលមានអាយុច្រើនជាងគេបង្អស់" នឹង "មានសម្បត្តិច្រើនជាងគេបង្អស់" មកឡើងកាន់អំណាចជាប្រធានាធីបតីនៃសហរដ្ឋអាមេរិក, តែក៏ជាប្រជានាធិបតីអាមេរិកដំបូងបង្អស់ ដែល "គ្មានបទពិសោធន៏ជាកងទ័ពនឹងមិនដែលបំរើក្នុងខាងរដ្ឋាភិបាល"ទេ នឹងជាប្រធានាធិបតីទី៥ ដែល"មិនបានឈ្នះឆ្នោតប្រជាមតិ-Popular Vote"ច្រើនជាងគេ ។

ជាមួយ ឌុណល ត្រម ភរិយារបស់លោក "មីឡាញ៉ា"បានឡើងមានតួរនាទីជាស្ត្រីទី១-

**តើមីឡាញ៉ាជានរណា?**

មីឡាញ៉ា ត្រម ស្ត្រីទី១នៅអាយុ៤៧ឆ្នាំ កើតកាលពីឆ្នាំ១៩៧0 នៅសាធារណរដ្ឋ "ស្លូវេញ៉ា" ជាផ្នែកមួយនៃប្រទេស"យូហ្គោស្លាវី", មកដល់អាមេរិកឆ្នាំ១៩៩៦, បាន "គ្រីនខត" ឆ្នាំ២០០១,



ចូលសញ្ជាតិអាមេរិកាំងនៅឆ្នាំ២០០៦, មានមុខរបរជាស្ត្រីបង្ហាញម៉ូតសម្លៀកបំពាក់កីឡាតប្រណិតយ៉ាងល្បីល្បាញ តាំងតែពីនៅយូហ្គោស្លាវីមកម្លេះ, ធ្លាប់ចេញនៅទំព័រមុខរបស់ទស្សនាវដ្តីធំៗជាច្រើន នៅស្រុកអ៊ីតាលី នៅបារាំងនឹងក្រោយបង្អស់នៅសហរដ្ឋអាមេរិកនេះ។

**តើអនុប្រធានាធិបតី ម៉ាយ ផែន ជានរណា?**

ម៉ាយ ផែន Michael Richard "Mike" Pence កើតនៅថ្ងៃ ៧មិថុនា ១៧៥៩ នៅ "កូឡិមប៊ឹស-រដ្ឋឥនឌ្យ៉ាណា" មុននឹងបានឡើងជាអនុប្រធានាទិបតី គឺជាអភិបាលរដ្ឋឥនឌ្យ៉ាណាពី



២០១៣ដល់២០១៧។ មានសញ្ញាប័ត្រខាងច្បាប់ចេញមកពី"សាកលវិទ្យាល័យឥនឌ្យ៉ាណា-រ៉ប៊ឹតម៉ាក់គិនហ្ស៊ី"។ បន្ទាប់ពីឈរឈ្មោះសភាជាតិមិនជាប់២ដង (១៩៨៨ នឹង ១៩៩0) លោកផែនបានទីធ្វើជាអ្នកបរិយាយវិទ្យុនឹងទូសទស្សន៏ពីឆ្នាំ ១៩៩៤-៩៩, ឆ្នាំ២000ក៏បានជាប់ជា "តំណាងសភាជាតិសង្កាត់លេខ២ នឹងលេខ៦នៃក្រុងឥនឌ្យាណា"នៅធ្វើការសភាជាតិពីឆ្នាំ២00១-២0១៣។ លោក ផែន ធ្លាប់ធ្វើជាប្រធានក្រុមប្រឹក្សាមហាសន្និបាទរបស់គណបក្សសាធារណរដ្ឋពីឆ្នាំ២00៩-២0១១។ លោក ម៉ាយ ផែន បានប្រកាសគោលជំហ៊រខ្លួនឯងថា ជា"មនុស្សមនោគមន៏វិជ្ជា" គាំទ្រចលនា "Tea Party Mouvment" គួរកត់សំគាល់ថា លោកជា "គ្រីស្ទាន-ប្រកាន់ទំនៀមទំលាប់-នឹងជាអ្នកប្រកាន់ទ្រឹស្តីសាធាររដ្ឋនិយម"។

នៅពេលលោក ឌុណល ត្រម ចូលកាន់កាប់សេដ្ឋវិមាន **តទៅទំព័រទី 0៤**

# លោក អ៊ុង រិទ្ធី ប្រធានថ្មីរបស់គណបក្សសង្គ្រោះជាតិសាខាសហរដ្ឋអាមេរិក

**ខ្មែរផុសស.រ.អា.**

គណកម្មការបោះឆ្នោតគណបក្សសង្គ្រោះជាតិសាខាសហរដ្ឋអាមេរិកដឹកនាំដោយលោក ម៉ារីត ឆាង ទើបនឹងតែងតាំងតាមរយៈការបោះឆ្នោតជ្រើសតាំងប្រធានគណកម្មការសាខាថ្មីរបស់ខ្លួនកាលពីថ្ងៃទី១៧ធ្នូ២០១៦ ផ្តល់ដំណែងប្រធានអាណត្តិ២ឆ្នាំ គឺលោក អ៊ុង រិទ្ធី, អនុប្រធានគឺលោក ម៉ារ៉ា ឈិន, នឹងអនុប្រធានទី២ គឺលោក ទិទ្យា ស៊ុំ ។

សូមរំលឹកថា សាខាគណបក្សសង្គ្រោះជាតិនៅអាមេរិកនេះមាន២ក្រុមមួយក្រុមដឹកនាំដោយលោក អ៊ុង រិទ្ធី មួយក្រុមទៀតដឹកនាំដោយលោក ជា គិមលី ប្រធានសាខាសហរដ្ឋអាមេរិកនឹងលោក ឆាន ទូច ប្រធានរដ្ឋម៉ាសាឈូសិតតែងតាំងដោយលោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិ។ លោក អ៊ុង រិទ្ធី ទើបនឹងជាប់ឆ្នោតបានបកស្រាយការបែកគ្នាជា២ក្រុមនេះថា "ថ្នាក់លើទទួលស្គាល់ទាំង២ក្រុមស្មើរគ្នាដោយយោងទៅតាមសេរីភាពក្នុងការជ្រើសរើសរបស់សមាជិកក្នុងតំបន់ -គោលដៅគឺមានតែមួយ គឺសំដៅទៅរកការឈ្នះឆ្នោតសាកលនៅឆ្នាំ២០១៧-១៨ខាងមុខ" ។

លោក អ៊ុង រិទ្ធី ធ្លាប់ជាសមាជិកក្រុមប្រឹក្សាសាលាក្រុងឡូវែល២អាណត្តិ, បច្ចុប្បន្នជាបុគ្គលិកសិក្សានៅវិទ្យាល័យឡូវែល។ ខ្មែរផុសស.រ.អា. បានធ្វើបទសម្ភាសន៍មួយនៅកន្លែងធ្វើការរបស់លោក កាលពីថ្ងៃទី១៣មករានេះ, នៅពេលសួរថា :

**ខ្មែរផុស**–តើតួនាទីជាប្រធានសាខាគណបក្សសង្គ្រោះជាតិមានទំនាស់អ្វីនឹងការងារដែលលោកកំពុងធ្វើដែរឬទេ?

**អ៊ុង រិទ្ធី** -អត់មានទេ ពីព្រោះតួនាទីជា "អ្នកពិគ្រោះការសិក្សារបស់សិស្សវិទ្យាល័យឡូវែល" នេះមានក្បួនច្បាប់ចែងច្បាស់លាស់!

**ខ្មែរផុស**–ក្នុងសាលានេះមានកូនសិស្សខ្មែរច្រើន ដូច្នេះក៏មានកូនសិស្សខ្លះ អាចជាកូនសមាជិកគណបក្សប្រជាជន តើលោកប្រកាន់ឥរិយាបទយ៉ាងណាចំពោះសិស្សទាំងនោះ?



លោក អ៊ុង រិទ្ធី

**អ៊ុង រិទ្ធី**– គឺត្រូវជួយសិស្សឱ្យស្មើគ្នាទាំងអស់មិនថា កូនអ្នកណាជាកូនអ្នកណាទេ ហើយម្យ៉ាងទៀតយើងមិនអាចបញ្ចេញអកប្បកិរិយាណាមួយបង្ហាញពីចំណូលចិត្ត ឬមិនពេញចិត្តដោយសារទសសនៈនយោបាយសិស្ស ឬគ្រួសាររបស់សិស្សបានទេ នេះជាវិន័យសាលា!

**ខ្មែរផុស** –ចុះនៅក្រៅសាលាវិញ សហគមន៍ខ្មែរនៅឡូវែលនេះ ក៏មានចំរុះគណបក្សដែរ តើលោកយល់យ៉ាងណាពីគណបក្សប្រជាជននៅទីនេះ?

**អ៊ុង រិទ្ធី**– នៅទីនេះពលរដ្ឋម្នាក់ៗសុទ្ធតែមានសិទ្ធរស់នៅសុខសាន្តស្មើៗគ្នាទាំងអស់, ខ្ញុំគ្រាន់តែឆ្ងល់ទេថា មកដល់ស្រុកសេរីហើយ ហេតុអ្វីក៏នៅស្រឡាញ់គណបក្សប្រជាជនធ្វើអ្វីទៀត តើមិន ឃើញថាគណបក្សនេះប្រព្រឹត្តអំពើផ្តាច់ការដែរឬទេ? អីចឹងបើយល់ថារបបផ្តាច់ការគ្រាន់បើតើ មករស់នៅទីនេះធ្វើអី? របបនៅទីនេះមិនដូចរបបនៅស្រុកខ្មែរទេ!

**ខ្មែរផុស** –តើលោកនៅទីនេះ ចូលជាសមាជិកគណបក្សសង្គ្រោះជាតិ តើអាចជួយអ្វីទៅស្រុកខ្មែរបាន?

**អ៊ុង រិទ្ធី** -ការជួយរបស់ខ្ញុំ គឺចង់លើកទឹកចិត្តប្រជាពលរដ្ឋឱ្យចង់មានការប្តូររបប, ចង់ជួយទប់ស្កាត់កុំឱ្យមានការរំលោភសិទ្ធមនុស្ស,ចង់ឱ្យមានការរីកចំរើនទៅដល់បងប្អូនដែលក្រីក្រតាមជនបទ, មិនចង់ឃើញពលរដ្ឋខ្មែរវេទនាដូច្នេះទេ!

**ខ្មែរផុស** -ទាំងនេះគ្រាន់តែជាទ្រឹស្តីទេ តើលោកនឹងនាំអ្វីដែលជាក់ស្តែងទៅជូនពលរដ្ឋខ្មែរ?

**អ៊ុង រិទ្ធី** –មានបងប្អូនជាច្រើន បានជួយជាលុយកាក់ជាអណ្តូងទឹក ជាសាលារៀន រួចហើយៗកំពុងតែធ្វើបន្តទៅទៀតដែរ, ចំណែកខ្ញុំ គឺមានខ្លួនខ្ញុំ ចំណេះខ្ញុំបទពិសោធន៍ខ្ញុំ ដែលខ្ញុំបរិច្ចាកដើម្បីឱ្យមានការផ្លាស់ប្តូរសង្គមសព្វថ្ងៃ ដែលបានធ្វើបាបពលរដ្ឋខ្លួនឯងនេះចេញ, ខ្ញុំនឹងណែនាំពីចម្ងាយតាមរយៈរចនាសម្ព័ន្ធនៅអាមេរិកនឹងទៅជួយស្រុកយើងដោយផ្ទាល់រួមសុខទុក្ខជាមួយបងប្អូននៅពេលខាងមុខ -ខ្ញុំនឹងណែនាំអ្នកឯទៀតឱ្យធ្វើដូចខ្ញុំឱ្យកាន់តែច្រើនឡើង!

**ខ្មែរផុស**– សូមអរគុណលោក អ៊ុង រិទ្ធី ចំពោះបទសម្ភាសន៍នេះ ៕

តមកទំព័រទី ០៣ **ពិធីសម្ពោធ...**

ហើយនឹងរដ្ឋបាលរបស់លោកចាប់ផ្តើមធ្វើការ...មនុស្សរាប់សែននាក់នៅកន្លែងរៀងៗខ្លួនផ្សេងទៀត (បើកសរុបទៅមានច្រើនលាននាក់) បានបន្តធ្វើបាតុកម្ម -កូដកម្មមានទាំងវាយឱ្យខូចហាងពាណិជ្ជកម្មដុតរថយន្ត...ច្រើនកន្លែងក្នុងស





ហរដ្ឋអាមេរិក ដូចជានៅ "បូស្តុន" នៅ "ឈីកាហ្គោ" នៅវ៉ាស៊ីនតោនឌីស៊ី" នឹងនៅវិមានប្រធានាធិបតី...។ល។ ពាក្យស្លោកសម្រាប់ស្ត្រីអាមេរិកាំងនៅរដ្ឋធានីវ៉ាស៊ីនតោន នាថ្ងៃទី២០ មករានោះ "ព្យុហ៍យាត្រារបស់ស្ត្រី" ក្នុងចំនួនច្រើនលាននាក់បានមករួមប្រជុំគ្នា ដើម្បីសម្តែងការមិនពេញចិត្តចំពោះប្រធានាធិបតីថ្មីដែលបានសម្តែងអកប្បកិរិយានឹងប្រើពាក្យសម្តីមើលងាយស្ត្រីទូទៅ គឺផ្តើមពីស្ត្រីដែលជាបេក្ខជនប្រឈមមុខនឹងត្រមក្នុងការដណ្តើមតំណែងប្រធានាធិបតីបន្តទៅស្ត្រីដែលមានតួនាទីតូចតាចស្ត្រីដែលកាន់សាសនាមូស្លីមក្នុងពិភពលោក...។ មិនត្រឹមស្ត្រីដែលនៅសហរដ្ឋអាមេរិកទេ ដែលចេញមកធ្វើបាតុកម្មដ៏ច្រើនសន្ធឹកសន្ធាប់នៅស្ទើរគ្រប់រដ្ឋតែនៅជុំវិញពិភពលោកក៏ដូចគ្នាដែរ បានចេញមកសម្តែងការបះបោរប្រឆាំងនឹងការមើលងាយស្ត្រីដូចគ្នានឹងនៅសហរដ្ឋអាមេរិកដែរ ៕



# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

AccuCare
Home Care Agency
Group Adults Foster Care Program

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើងដែលមានបញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។




**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**

- រស់នៅផ្ទះរដ្ឋ
- អាយុ ២២ ឆ្នាំឡើងទៅ
- មាសហែលស្តង់ដា

**ផលប្រយោជន៏ទទួលបាន :**

- ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការ រស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក ២៤ម៉ោង

***To be eligibled for GAFC you must:***

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

## ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

# សាលាក្រុងបានតម្លើងពន្ធផ្ទះដោយគ្មានការជជែកគ្នា

## The city of Lowell approved the rise of Property tax without discission

**ខ្មែរផុសស.រ.អា.**

ពន្ធលើអចលនវត្ថុបានត្រូវសមាជិកក្រុមប្រឹក្សាក្រុងឡូវែលសម្រេចឱ្យតម្លើងជាង៥% នាឆ្នាំនេះ ដោយគ្មានការជជែកវែកញែក ពីព្រោះគេយល់ថា ប្រាក់ពន្ធនេះត្រូវតែតម្លើងជាចាំបាច់ ប្រសិនបើក្រុងមិនចង់ឱ្យជំពាក់គេទេ។ ម្ចាស់ផ្ទះនិមួយៗនៅឡូវែលនេះ នឹងឃើញវិក័យប័ត្រ "ពន្ធដារផ្ទះ-ប្រពីទីតាក់" មានតម្លៃ១៨៩ដុល្លា, ច្រើនជាងប្រាក់ពន្ធផ្ទះដែលគេបានបង់ពីឆ្នាំមុនដែលមានចំនួនបន្ថែមតែ១១៩ដុល្លាតែប៉ុណ្ណោះ គឺតម្លើងតែ៣,៥ភាគរយច្រើនជាងកាលពី២ឆ្នាំមុន។

លោកអភិបាលក្រុងឡូវែល **អេដ កេណ្ណឌី** បាននិយាយប្រាប់កាសែត "ឡូសាន់" ថា "យើង



Mayor Ed Kennedy

ខំរក្សាប្រប្រីទីតាក់មិនឱ្យឡើងខ្ពស់ទេ ប៉ុន្តែការតម្លើងឆ្នាំនេះវាសមរម្យហើយ" លោកបន្ថែមថា "ដោយមិនចង់តម្លើងតាក់ដែលនាំឱ្យធ្ងន់ដល់ពលរដ្ឋមានឆ្នាំខ្លះ មិនបានតម្លើងពន្ធទាល់តែសោះតែដល់ពេលត្រូវតម្លើង ក៏តម្លើងយ៉ាងខ្ពស់តែម្តង, នេះជាការមិនសមរម្យទេ គេគួរតម្លើងដែរតែម្តងបន្តិច ទើបមិនមានការប៉ះពាល់"។ សាលាក្រុងបានមើលឃើញថា ការតម្លើងពន្ធនេះវាជាការចាំបាច់ បើទោះជាជជែកគ្នាក៏ត្រូវតែតម្លើងដែរ..."។

**អាដាម ព្រិល** "អាយតិច" តំណាងឱ្យពាណិជ្ជករ



Adam pril

នៅ "ខពលស្តែរ" និយាយដោយមិនពេញចិត្តថា "គេមិនគួរតម្លើងប្រាក់ពន្ធច្រើនយ៉ាងនេះ ដោយគ្មាន ការពិគ្រោះគ្នាឱ្យពលរដ្ឋបានយល់ច្បាស់ផងនោះទេ គួរណាស់តែមានការប្រជុំពន្យល់ប្រជាពលរដ្ឋឱ្យបានយល់ច្បាស់មុននឹងកាត់លុយគេផង សហគមន៍ខ្មែរដ៏ធំនៅឡូវែលនេះ មិនបានយល់ពីរឿងនេះទេ!"។

បើប្រៀបធៀបទៅនឹងក្រុងឯទៀតៗនៅក្បែរគ្នា តម្លៃពន្ធនៅឡូវែលនេះ ស្មើនឹង ១ភាគ៣ នៃពន្ធលើអចលនវត្ថុនៃតំបន់ជុំវិញតែប៉ុណ្ណោះ ឃើញថានៅថោកជាងគេច្រើននៅឡើយ។ **ស ចៃល** ធ្វើការរនៅប៉ូលីសតុលាការឡូវែល និយាយថា "បើគេចង់ឱ្យកូនរៀនសាលាឯកជនដែលមានបង់ថ្លៃសាលាខ្ពស់គេគួរមានផ្ទះនៅឡូវែល ពីព្រោះពន្ធផ្ទះវាថោកជាងគេ ហើយយកប្រាក់ចំណេញពីពន្ធផ្ទះនោះ ទៅបង់ថ្លៃសាលាកូន"។

លោក ខេវិន ម៉រហ្វី ចាងហ្វាងសាលាក្រុង និយាយថា "ការតម្លើងពន្ធនេះ វាចាំបាច់ណាស់សម្រាប់ទប់ទល់ការឡើងថ្លៃភ្លើង,ឡើងថ្លៃធានារ៉ាប់រង, ឡើងប្រាក់ខែ នឹងសេចក្តីត្រូវការផ្សេងៗក្រៅពីនេះក៏មានការវិនិយោគរបស់ក្រុងបន្ថែមទៀតដែរ។ សាលាក្រុងឡូវែលមានគម្រោងធំៗដូចជាត្រូវចំណាយរាប់លានបន្ថែមសម្រាប់បង្កើតឱទ្យាននឹងកែលំអធ្វើផ្លូវ "ឡូវេណ" នឹងធ្វើស្ពាននៅលើស្ទឹង "ខនខូដ"...។ សមាជិកក្រុមប្រឹក្សាក្រុងកាន់ខាងគណកម្មការហិរញ្ញវត្ថុ **ជឹម រិទ្ធី** បរិយាយថា "ការតម្លើងពន្ធនេះមិនមែនជាចៃដន្យទេ ក្រុមប្រឹក្សាក្រុងបានបោះឆ្នោតកាលពីរដូវក្តៅមុនឱ្យកែលំអ "ថវិការក្រុង" តែថវិការនោះវាចង្អៀតណាស់ទៅហើយដូច្នេះត្រូវទប់ទល់នៅឆ្នាំនេះ ហើយឆ្នាំក្រោយក៏ដូចគ្នាដែរ។ សាលាក្រុងឡូវែលប្រើប្រាស់ថវិការ៣៤១លានដុល្លាសម្រាប់ដំណើរ



Vesna Nuon



លោក ជឹម រិទ្ធី



លោក ស ចៃល

ការ រហូតដល់ខែមិថុនា ដែលថវិការនេះខ្ពស់ជាងថវិការឆ្នាំមុនចំនួន៦លានដុល្លា។ យោងតាមតារាងកាត់ប្រាក់ពន្ធលើផ្ទះជា "លំនៅឋាន" និមួយៗក្នុងក្រុង គឺក្នុងរៀងរាល់១,000ដុល្លាថ្លៃផ្ទះ គេយក ១៤,៩២ដុល្លា រីឯផ្ទះជាហាងពាណិជ្ជកម្មវិញ គេយកតម្លៃ៣0,៦៤ដុល្លា។ ជាទូទៅម្ចាស់ផ្ទះក្នុងគ្រួសារនិមួយៗនៅឡូវែលនឹងចេញប្រាក់ពន្ធលើផ្ទះរបស់ខ្លួនក្នុង១ឆ្នាំ២0១៧នេះ ៣,៧៨៨ដុល្លា, តែបើប្រៀបធៀបទៅនឹងឆ្នាំមុន២0១៦ ក្រុងទារតែ៣,៥៩៩ទេ។

**វ៉ាស្នា នួន** អតីតក្រុមប្រឹក្សាក្រុងឡូវែល បាននិយាយថា "ក្រុមប្រឹក្សាក្រុងមានភារកិច្ចពិភាក្សាពីការតម្លើងពន្ធនេះ ពីព្រោះពលរដ្ឋក៏

**តទៅទំព័រទី 0៨**






# ACTIVE DAY® | SENIOR CARE®

**Under the same management as Lowell Elder Care**

# មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល

**345 Chelmsford St. Lowell, MA 01851/ -www.seniorcarectrs.com and www.activeday.com**

**អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?**

គឺជាលំនៅដ៏កក់ក្តៅមួយដែលផ្តល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យ មានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ។ កម្មវិធីរបស់យើងធានានូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាស ដូចជាផ្ទះរបស់ពួកគាត់ ។

**ទីតាំងនៃមណ្ឌល**

ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និងមានពន្លឺ គ្រប់គ្រាន់ បន្ទប់អានសៀវភៅបន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។





**មណ្ឌលផ្តល់សេវាដល់មនុស្សចាស់**

- មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
- ការពិនិត្យ និងថែទាំសុខភាព
- ការព្យាបាលតាមរយៈការហាត់ប្រាណ
- កិច្ចការសង្គម (ផ្តល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ)
- ម្ហូបខ្មែរក្តៅៗ និងចំណីផ្សេងៗ
- ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
- កម្មវិធីសិល្បៈ និងតន្ត្រី
- ការអប់រំពីសុខភាព
- ពិធីបុណ្យខ្មែរ និងព្រឹត្តិការណ៍សាសនា
- សកម្មភាព និងដំណើរកំសាន្តក្រៅមណ្ឌល

**Open 7 Days a Week**

- Door-to-Door Transportation
- Medical Care and Support
- Physical Therapy
- Social Worker
- Khmer Meals and Snacks
- Adaptive Physical Exercise
- Music Programs
- Health Educational Seminars
- Observe Khmer Holidays & Religious Events
- Outdoor Field Trips

**សូមហៅលេខទូរស័ព្ទ (978) 596-1111**

# លោក ម៉ាយរ វាល ប្រកាសពីការពង្រើកនៃការមិនបង់ថ្លៃសិក្សា

បន្ថែមទៅលើ MassBay ឥឡូវនេះមាន ជម្រើសចំនួនបីរសម្រាប់ការបង់ថ្លៃ ចំពោះសិស្ស ដែលបញ្ចប់ការសិក្សានៅសាលាប៊ូសស្តូន (BPS)

**ប៊ូសស្តូន** - ថ្ងៃសុក្រ ទី៣០ ខែធ្នូ ឆ្នាំ ២០១៦ -លោក ម៉ាយរ ម៉ាទី វាល (Mayor Walsh)



លោកអភិបាលក្រុង ម៉ាទី វាល

បានប្រកាសនៅថ្ងៃនេះថា គម្រោងនៃការមិន បង់ថ្លៃសិក្សាររបស់ក្រុងប៊ូសស្តូន (The City of Boston’s Tuition-Free Community College Plan) ដែលតំរូវឱ្យសិស្សនៅក្រុងប៊ូសស្តូនដែល ទទួលលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់គម្រោង នេះធ្វើការបង់ថ្លៃការសិក្សាររបស់ខ្លួនរហូតដល់ ទៅបីរឆ្នាំនោះ បានត្រូវពន្យាពេលក្នុងការចុះ ឈ្មោះចូលរៀន រហូតដល់បញ្ចប់ការសិក្សា Mass Bayជាមុនសិន។

លោក ម៉ាយរ វ៉ាស បានមានប្រសាសន៍ថា "ខ្ញុំសូមធ្វើការប្រកាស់ពីការបន្ថែមនៃ Mass Bay ទៅក្នុងគម្រោងនៃការមិនបង់ថ្លៃសិក្សារបស់ក្រុង ប៊ូសស្តូន។ យើងនឹងប្រឹងប្រែងធ្វើយ៉ាងណា ដើម្បី បង្កើនការទទួលបានការអប់រំកំរិតខ្ពស់ឱ្យកាន់តែ ច្រើនឡើង និងបើកច្រកផ្លូវច្រើនបន្ថែមទៀត សម្រាប់ស្ថេរភាពផ្នែកសេដ្ឋកិច្ចដល់សិស្សនៅក្នុងក្រុង ប៊ូសស្តូនទាំងអស់"។ "បច្ចុប្បន្ននេះ ដោយមានការ កើនឡើងនូវទីកន្លែង និងជម្រើសកម្មវិធីសិក្សា គម្រោងនេះ បើកច្រកកាន់តែច្រើនឡើងសម្រាប់ យុវជន ដើម្បីសិក្សា និងអភិវឌ្ឍន៍នូវជំនាញរបស់ ខ្លួនដែលចាំបាច់សម្រាប់ចូលរួមក្នុងកំលាំងការងារ ក្នុងក្រុងប៊ូសស្តូន"។

MassBay Community College គឺជា សាលាដែលមានទីតាំងច្រើន មានប្រវត្តិ៥៥ឆ្នាំ មកហើយក្នុងការរៀបចំសិស្សានុសិស្សសម្រាប់ បន្តការសិស្សារថ្នាក់វិទ្យាល័យ ឬមហាវិទ្យាល័យ ដែលមានរយៈពេល៤ឆ្នាំ ឱ្យចូលរួមដោយផ្ទាល់ ទៅក្នុងកំលាំងពលកម្ម និងការសិស្សាបន្ត។

លោក ដេវីត ផូដែល ដែលជាប្រធាន MassBay Community College បានមានលើក ឡើងថា "គម្រោង MassBay មានសកម្មភាព យូរមកហើយក្នុងការបើកច្រកដែលមានគុណភាព ខ្ពស់ និងតម្លៃសមរម្យចំពោះកម្មវិធីសិក្សាថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ និងជំនាញដែលចាំបាច់"។ លោកក៏បានបន្ថែមទៀតថា "យើងមានការរីករាយ ដែលបានចាប់ដៃគូរជាមួយសាលាក្រុង ដើម្បីបង្កើន ការចុះឈ្មោះចូលសិក្សារថ្នាក់វិទ្យាល័យ និង ពង្រើកនូវជម្រើសជាច្រើនទៀតសម្រាប់សិស្ស នៅប៊ូសស្តូនដែលត្រូវការជាចាំបាច់បំផុតនោះ"។

គម្រោងនៃការមិនបង់ថ្លៃសិក្សារនេះ កាលពី មុនអនុញ្ញាតឱ្យចុះឈ្មោះតែសិស្សដែលមានសិទ្ធ ទទួលបានប៉ុណ្ណោះ ក្នុងការសិក្សារនៅសាលា Bunker Hill Community College (BHCC) និង Roxbury Community Collge (RCC). ការដាក់បញ្ចូលបន្ថែមនៃ MassBay Community College នេះ ផ្តល់ឱ្យសិស្សដែលមានគម្រោងចុះ ឈ្មោះសិស្សារនូវជម្រើសទាំងពីទីកន្លែង ក៏ដូចជា ការកម្មវិធីសិក្សារច្រើនជាងមុន។ MassBay មានទីតាំងរបស់ខ្លួនដូចជានៅរដ្ឋ វីលលី ( Wellesley) ហ្វេមម៉ីងហែម (Framingham) និងអាសលិន (Ashland). MassBay ក៏មានបន្ថែមកម្មវិធី សិក្សាជាច្រើនទៀតដូចជា បច្ចេកទេសផ្នែកយាយន្ត ការឱហ្សាង និងផ្នែកទីផ្សារ។

លោក ម៉ាយរ វាល បានប្រកាស់ពីការចាប់ ផ្តើមដំណើរការគម្រោងនៃការមិនបង់ថ្លៃសិក្សា នេះកាលពីនិទាឃរដូវមុនក្នុងគោលបំណង ដើម្បី ជួយសិស្សានុសិស្សច្រើនជាងមុនក្នុងក្រុងប៊ូសស្តូន ឱ្យមានលទ្ធភាពបង់ប្រាក់សិក្សា និងបញ្ចប់ការ សិស្សារបស់ខ្លួន។ ដើម្បីជួយសិស្សក្នុងការបញ្ចប់ ថ្នាក់វិទ្យាល័យគម្រោងនេះ គឺវាសមស្របរាល់ សិស្សទាំងអស់ដែលមានលោកគ្រូអ្នកគ្រូបំរើការងារ ក្នុងគម្រោង Boston Success ដែលអាចជួយ សិស្សទាំងនោះ ក្នុងការដោះស្រាយនូវឧបសគ្គ ក្នុងការសិក្សារថ្នាកខ្ពស់នោះ។ នៅក្នុងឆមាស ទី១ គម្រោងនៃការបង់ថ្លៃសិក្សានេះ មានសិស្ស ចុះឈ្មោះចំនួន៤១នាក់ ដែលចំនួនរំពឹងទុកនឹង កើនឡើងនៅពេលដែលការយល់ដឹងពីអត្ថ-ប្រយោជន៍នៃគម្រោងនេះ កាន់តែរីកសាយ ភាយកាន់តែទូលំទូលាយ។

គម្រោងនេះ គឺមានការជួយឧបត្ថមពី ការ-វិយាល័យអភិវឌ្ឍន៍កំលាំងពលកម្មរបស់ ម៉ាយរ (Mayor’s OWD) ដែលជាផ្នែកមួយនៃ ទីភ្នាក់ងារអភិវឌ្ឍន៍ និងផែនការក្រុងប៊ូសស្តូន និង Neighborhood Jobs Trust (NJT) ដែល ជាអង្គការសប្បុរសធមិដំណើរការដោយមាន ប្រាក់កម្រៃដែលបានមកពីគម្រោងអាគារពាណិជ្ជ កម្មធំៗក្នុងក្រុង។

លោក ប្រិន គូលដិន (Brian Golden) អគ្គនាយនៃទីភ្នាក់ងារអភិវឌ្ឍន៍ និងផែនការ ក្រុងប៊ូសស្តូនបានមានប្រសាសន៍ថា "ការផ្តល់ ឱកាសសម្រាប់អ្នករស់នៅក្រុងប៊ូសស្តូនក្នុងការ ចូលរួមបង់ប្រាក់សិស្សា គឺជាផលប្រយោជន៍ ដោយផ្ទាល់មួយនៃការកើនឡើងនៃអាគារ និង សេដ្ឋកិច្ចដ៏រឹងមាំរបស់ក្រុងប៊ូសស្តូន"។ "យើងដឹង ថា វាមានផលប្រយោជន៍ច្រើន ដូចជាសេដ្ឋកិច្ច និងផ្នែកផ្សេងៗទៀត ដល់សិស្សានុសិស្សដែល បានទទួលការសិស្សារពីគម្រោងនេះ ក្នុងមួយ ជីវិតរបស់ពួកគេ"។ លោកក៏មានបន្ថែមទៀតថា ខ្ញុំមានការរីករាយដែលយើងអាចប្រើប្រាស់ មូលនិធិពី NJT ដើម្បីធ្វើការវិនិយោគជាវិជ្ជមាន ជាច្រើន ដែលនឹងមានឥទ្ធិពលរយៈពេលនៅ ក្នុងសហគមន៍របស់យើង។

ដើម្បីយល់ដឹងបន្ថែមអំពីគម្រោងនៃការ បង់ថ្លៃសិក្សាររបស់ក្រុងប៊ូសស្តូន ឬចុះឈ្មោះ សូមចូលទៅកាន់ http://www.bostonpublic-schools.org/tuition-fee-college

City of Boston, 1 City Hall Square, Boston, MA 02201SafeUnsubscribeTM

sobenpin@khmerpost.us

តមកពីទំព័រទី ០៧

## សាលាក្រុងបានតម្លើងពន្ធផ្ទះ...

មានភារៈកិច្ចពិនិត្យថវិកាក្នុងផ្ទះរបស់ខ្លួនដែរ បើប្រាក់ខែខ្លួនមានកំរិតតើឱ្យគ្នាទៅយកលុយពី ណាមកៗបង់ឱ្យការតម្លើងពន្ធនេះរាល់តែឆ្នាំនោះ បើប្រាក់ខែមិនឡើងនោះ, ឆ្នាំនេះឃើញថា ឥតសូវ មានធ្លាក់"ស្នូវ"ទេ គេអាចបង្វិលចំណាយនេះទៅចាយលើអ្វីផ្សេងបានទេតើ មិនចាំបាច់តម្លើងពន្ធ បានទេ? គេថាតាក់ក្រុងយើងទាប! បើប្រៀបធៀបទៅក្រុងឯទៀតដែលនៅក្បែរៗយើង ហេតុអ្វីក៏គេ មិនប្រៀបធៀបគុណភាពសាលារៀនគេ គុណភាពក្រុងគេជាមួយនឹងយើងផង? ខ្ញុំសង្កេតឃើញថា លោក"ម័រហ្វី"តម្លើងតាក់រាល់ឆ្នាំហើយនៅបន្តិចទៀតនឹងមានអ្វីតម្លើងទៀតដូចជា"ហ្វី"តម្លៃធ្វើលិខិត នានានៅសាលាក្រុងគេនឹងពិគ្រោះជាមួយពលរដ្ឋដែរឬទេ?"

អាដាម ព្រិល យល់បន្តថា "សហគមន៏គួរតែជួបជុំពិចារណាជាមួយគ្នាអំពីការតម្លើងប្រាក់ពន្ធ លើអចលនវត្ថុនេះ ពីព្រោះយើងមិនអាចចេះតែបង់តាមតែគេទារដោយមិនបានដឹងថា តើគេយក ទៅចំណាយអ្វីខ្លះនោះទេ, ក្រុងអាចនាំគ្នាតម្លើងប្រាក់ខែនៅលើការខិតខំរកស៊ីរបស់ពលរដ្ឋខ្លួនឯង ក៏ថា បានដែរ បើយើងមិនបានតាមដាននោះ!"៕




# For your special day...

## សម្រាប់ថ្ងៃដ៏ពិសេសរបស់អ្នក







**The UMass Lowell Inn & Conference Center** provides timeless, modern elegance with a relaxing atmosphere.

You and up to 450 guests will be catered to by our attentive staff, while you celebrate in style and comfort.

We offer overnight lodging, scenic outdoor photo opportunities, and a variety of ceremony spaces, including smaller rooms for showers, rehearsal dinners, and engagement parties.

All of our menus can be personalized to suit your individual needs.

**សណ្ឋាគារ យូម៉ាសឡូវែលនឹងមណ្ឌលប្រជុំ**
ផ្តល់ជូនយ៉ាងទាន់ចិត្ត ជឿនលឿន សង្ហា ជាមួយនឹងបរិយាកាស យ៉ាងរំភើយ

លោកអ្នកនឹងភ្ញៀវរហូតដល់៤៥០នាក់អាចនឹងជប់លៀង ដោយមានការយកចិត្តទុកដាក់ពីបុគ្គលិកយើង នៅពេលដែលលោកអ្នកកំពុងរៀបពិធី ប្រកបដោយសម្បូរបែបនឹងយ៉ាងកក់ក្តៅ ។

យើងផ្តល់ជូនការស្នាក់អាស្រ័យឆ្លងរាត្រី, ទីធ្លាខាងក្រៅគួរឲ្យរំភើបសម្រាប់ មានឱកាសថតរូបនឹងបន្ទប់សម្រាប់ពិធីការគ្រប់ធុន,

រាប់ទាំង បន្ទប់តូច សម្រាប់បង្ហក់កូន, ត្រៀមសម្រាប់ជប់លាងអាហារពេលល្ងាចនឹងពិធី ភ្ជាប់ពាក្យ...។
គ្រប់បញ្ជីមុខម្ហូបអាចនឹងរៀបចំជូនស្របតាមតម្រូវការរបស់បុគ្គលម្នាក់ៗបាន ។

Inn & Conference Center
UMASS LOWELL

**UMass Lowell Inn & Conference Center**
50 Warren St., Lowell MA 01852 978-934-6920 877-886-5422
**www.uml.edu/icc**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# CPP អបអរ "ថ្ងៃកំណើតទី២" ខណៈលោក កឹម សុខា ទៅគោរពផ្នូរ កែម ឡី

**ដោយបែន សុខហ៊ាន | ថ្ងៃច័ន្ទ ទី៩ខែមករា ឆ្នាំ២០១៧**

ខណៈគណបក្សប្រជាជនកម្ពុជារៀបចំពិធីយ៉ាងអធិកអធមសម្បើមអមដោយការឃោសនានៅទីស្នាក់ការកណ្ដាលរបស់ខ្លួនក្នុងរាជធានីភ្នំពេញកាលពីថ្ងៃសៅរ៍?ដើម្បីអបអរសាទរការដួលរលំនៃរបបខ្មែរក្រហមលោក កឹម សុខា ប្រធានស្ដីទីនៃគណបក្សសង្គ្រោះជាតិបានហែក្បួនទៅកាន់ផ្នូរលោក កែម ឡី អ្នកវិភាគនយោបាយដែលត្រូវខ្មាន់កាំភ្លើងធ្វើឃាត ដល់ខេត្តតាកែវ ។

គណបក្សកាន់អំណាចចាត់ទុកថ្ងៃ៧មករា ឬថ្ងៃជ័យជម្នះជាកំណើតទី២របស់កម្ពុជា បន្ទាប់ពីការគ្រប់គ្រងដ៏ព្រៃផ្សៃរបស់ ប៉ុល ពត ខណៈមនុស្សជាច្រើននៅក្នុងគណបក្សប្រឆាំងចាត់ទុកវាជាការចាប់ផ្ដើមការត្រួតត្រារយៈពេល១ទសវត្សរ៍ពីសំណាក់ប្រទេសវៀតណាមដែលខ្លួននិយាយថាបន្តប្រើប្រាស់ឥទ្ធិពលមិនត្រឹមត្រូវមកលើគណបក្សប្រជាជនកម្ពុជា ។

ចូលរួមជាគណៈអធិបតីនៃពិធីរបស់គណបក្សកាន់អំណាចនេះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលជាប្រធានគណបក្សប្រជាជនកម្ពុជា បានថ្លែងសុន្ទរកថាផ្ដោតសំខាន់លើការនឹកអាឡោះអាល័យដល់អតីតកាល និងការព្រមានអ្នកដែលប្រឆាំងរបបរបស់លោក ។

លោក ហ៊ុន សែន បានចាត់ទុកថ្ងៃ៧មករាជា "ជ័យជម្នះជាប្រវត្តិសាស្ត្ររបស់ប្រជាជនកម្ពុជាដែលបានផ្ដួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត បញ្ចប់សម័យកាលដ៏ខ្មៅងងឹតបំផុតនៃកម្ពុជា ហើយបើកឡើងនូវទំព័រសករាជថ្មី គឺឯករាជ្យ សេរីភាព ប្រជាធិបតេយ្យ និងវឌ្ឍនភាពសង្គម" ។

ចំពោះអ្នកផ្សេងដូចជាលោក សម រង្ស៊ី ប្រធានគណបក្សប្រឆាំងដែលមើលមិនឃើញតម្លៃអ្វីដែលគួរអបអរសាទរនៅថ្ងៃ៧មករាជាដើម លោក ហ៊ុន សែន មានប្រសាសន៍ថា សាររបស់ពួកគេគឺបង្ហាញច្បាស់ហើយ ។

លោកបានលើកឡើងយ៉ាងដូច្នេះថា "មានតែអ្នកចង់ឱ្យរបបប្រល័យពូជសាសន៍វិលត្រឡប់មកវិញ?និងអ្នកដែលចង់ប្រើប្រាស់កម្ពុជាដើម្បីសម្រេចគោលបំណងអាក្រក់របស់ខ្លួន ដោយពុំគិតដល់អាយុជីវិតរបស់ប្រជាជនកម្ពុជាប៉ុណ្ណោះដែលប្រឆាំងនឹងជ័យជម្នះ៧មរា" ។

ឆ្លៀតក្នុងឱកាសនោះ លោកនាយករដ្ឋមន្ត្រីបានគូសបញ្ជាក់ពីការពាក់ព័ន្ធដ៏ស្មុគស្មាញរបស់ប្រទេសមហាអំណាចនៅក្នុងប្រវត្តិសាស្ត្រដ៏មហន្តរាយ ដែលបានកើតឡើងនៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០នេះ ហើយបានបញ្ជាក់ថា គណបក្សរបស់លោកនឹងធានាមិនឱ្យការជ្រៀតជ្រែកបែបនេះកើតឡើងទៀតឡើយ ។

លោកបានបន្តថា "យើងទាំងអស់គ្នាប្រឆាំងដាច់ខាតនូវរាល់សកម្មភាពប្រទូសរ៉ាយ ទោះបីចេញពីប្រភពណាក៏ដោយដែលអាចធ្វើឱ្យខ្មែរបែកបាក់គ្នាជាថ្មីទៀត" ហើយលោកបានបញ្ជាក់ជាថ្មីម្ដងទៀតថា រដ្ឋាភិបាលនឹងមិនអត់ឱនឱ្យឡើយចំពោះ "បដិវត្តន៍ពណ៌" ដែលបង្កឡើងដោយជនបរទេសបង្ករឿងដែលលោកមិនបញ្ចេញឈ្មោះ ។

បន្ទាប់ពីបញ្ចប់សុន្ទរកថារបស់លោក លោក ហ៊ុន សែន និងលោក ហេង សំរិន ប្រធានរដ្ឋសភា និងជាប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជា បានលែងសត្វព្រាបខណៈប៉េងប៉ោងរាប់រយហោះឡើងទៅលើមេឃអមដោយបដាសរសេរថា "គណបក្សប្រជាជនកម្ពុជាបាននាំមកនូវសន្តិភាព ស្ថិរភាពនិងការអភិវឌ្ឍន៍" ។

មុនពេលចាកចេញទៅវិញ លោក ហ៊ុន សែន បានដើរទៅកាន់អ្នកចូលរួមដើម្បីចាប់ដៃស្វាគមន៍ និងថតរូបសែលហ្វី ។

ទោះជាយ៉ាងណា ខណៈគណបក្សប្រជាជនកម្ពុជាកំពុងប្រារព្ធអបអរសាទរ?លោកកឹម សុខាប្រធានស្ដីទីនៃគណបក្សសង្គ្រោះជាតិបានធ្វើដំណើរទៅកាន់ខេត្តតាកែវដើម្បីបួងសួងនៅពី

តទៅទំព័រទី ១៩




# CPP HONORS 'SECOND BIRTH'; SOKHA VISITS KEM LEY'S GRAVE

**by Ben Sokhean | January 9, 2017**

As the CPP put on a dazzling display of pomp and propaganda at its Phnom Penh headquarters on Saturday to mark the anniversary of the fall of the Khmer Rouge, acting CNRP President KemSokha paid a pilgrimage to the grave of slain political analyst Kem Ley in Takeo province.

The ruling party sees January 7, or Victory Day, as marking Cambodia's rebirth after Pol Pot's murderous rule, while many in opposition circles see it as the beginning of a decadelong occupation by Vietnam, which they say continues to exert undue influence on the CPP.

Prime Minister Hun Sen, center, presides over a ceremony at the CPP's headquarters in Phnom Penh on Saturday. (Siv Channa/The Cambodia Daily)

Presiding over the ruling party's ceremony, Prime Minister Hun Sen, who is also president of the CPP, delivered a speech heavy on nostalgia and warnings toward those who oppose his regime.

Mr. Hun Sen described January 7 as marking "the historic victory of the Cambodian people in overthrowing the regime of Pol Pot's genocide, ending the darkest period in Cambodia and ushering in a new era of independence, freedom, democracy and social progress."

To those such as opposition leader Sam Rainsy who see nothing to celebrate on January 7, Mr. Hun Sen said their message was clear.

"Only those who wish to have a genocidal regime return to Cambodia would use Cambodia for their own perfidious ends-without thinking of the life of Cambodian people-and oppose the January 7 victory," he said.

The prime minister used the occasion to note the inextricable involvement of foreign powers in the disastrous history that unfolded in the 1970s, and said his party would ensure that such meddling would not be repeated.

"We resolutely oppose controversial actions, regardless of their source, that may divide Cambodia again," he said, reciting a common refrain that the government would not tolerate a "color revolution" aroused by unnamed foreign provocateurs.

After finishing his speech, Mr. Hun Sen and National Assembly President HengSamrin, the party's honorary president, released white doves as hundreds of balloons floated to the sky along with a banner with the message: "The CPP brought peace, stability and development."

Prime Minister Hun Sen, right, and National Assembly President HengSamrin watch the release of balloons during a ceremony in Phnom Penh on Saturday marking the fall of the Khmer Rouge. (Siv Channa/The Cambodia Daily)

Before departing, Mr. Hun Sen toured the crowd to shake hands and pose for selfies.

As the CPP was celebrating, Mr. Sokha, the acting CNRP president, visited Takeo province, where he prayed at the grave of slain political analyst Kem Ley and met with his family, posting photographs of the trip to Facebook.

"This is the first time that I have come to pay respect to the soul of Mr. Dr. Kem Ley at his tomb in his house," Mr. Sokha wrote in an accompanying message, adding that the last time the two met, the conversation focused on commune election strategies.

"I wish the soul of Mr. Dr. Kem Ley rest in peace," he wrote of the analyst, who was shot dead in July in what many believe was a political assassination. "I still continue to seek justice for mister doctor."

Opposition leader Sam Rainsy, who has been officially exiled from the country, took to Facebook for what has become his own tradition on January 7,

**Continued to Page 18**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីគេហទំព័រ ... អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# យុទ្ធនាការថ្ងៃច័ន្ទពណ៌ខ្មៅចាប់ផ្តើមឡើងវិញ ខណៈមន្ត្រីសមាគមអាដហុកជាប់ពន្ធនាគារនៅឡើយ

**ដោយ សេក ឧត្តម | ថ្ងៃអង្គារ ទី១០ខែមករា ឆ្នាំ២០១៧**

យុទ្ធនាការថ្ងៃច័ន្ទពណ៌ខ្មៅដ៏អូសបន្លាយបានចាប់ផ្តើមឡើងវិញកាលពីម្សិលមិញ ដើម្បីឆ្លើយតបទៅនឹងការបន្តឃុំខ្លួនមន្ត្រីបួនរូបមកពីសមាគមសិទ្ធិមនុស្សអាដហុក និងមន្ត្រីគ.ជ.ប.មួយរូប ថ្វីបើមានការរំពឹងទុកថា ពួកគាត់នឹងទទួលបានការដោះលែងត្រឹមដំណាច់ឆ្នាំក្តី។

ក្រុមអ្នកតវ៉ាបានប្តេជ្ញាបន្តយុទ្ធនាការនេះរហូតទាល់តែក្រុមនេះត្រូវបានដោះលែង។

ក្តីសង្ឃឹមបានកើនឡើងកាលពីដើមខែមុន នៅពេលមានសេចក្តីរាយការណ៍ថា លោក កឹម សុខា ប្រធានស្តីទីនៃគណបក្សសង្គ្រោះជាតិ និងលោកនាយករដ្ឋមន្ត្រីហ៊ុនសែនចាប់ផ្តើមចរចា ដើម្បីដោះលែងមន្ត្រីសិទ្ធិមនុស្សទាំងបួនរូប និងលោកនីចរិយាជាមន្ត្រីគ.ជ.ប.ដែលពីមុនធ្លាប់បម្រើការងារនៅសមាគមអាដហុកចេញពីពន្ធនាគារ បន្ទាប់ពីជាប់ឃុំអស់រយៈពេល៨ខែ។

ទោះជាយ៉ាងណា ខណៈក្រុមនេះបន្តជាប់ពន្ធនាគារ ហើយមិនទាន់មានការកំណត់កាលបរិច្ឆេទសម្រាប់ការចរចាបន្ថែមទៀតនៅឡើយ រវាងគណបក្សធំៗទាំងពីរសកម្មជនប្រមាណ២០រូបបានធ្វើការតវ៉ានៅសហគមន៍បឹងកក់ដែលរងការបណ្តេញចេញ។ ការតវ៉ាកាលពីព្រឹកម្សិលមិញនេះគ្មានការប្រវាយប្រតប់គ្នាជាមួយនគរបាល និងការចាប់ខ្លួនឡើយពោលគឺមិនដូចការតវ៉ាជាច្រើនលើកមុនៗនោះទេ។

កាលពីសប្តាហ៍មុនលោក កឹម សុខា បានស្នើសុំជួបជាមួយលោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃដែលបានទទួលយកសំណើនេះ ប៉ុន្តែមិនបានកំណត់កាលបរិច្ឆេទជួបគ្នានោះទេ។ ទន្ទឹមនឹងនេះនៅសប្តាហ៍នេះលោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិចោទប្រកាន់រដ្ឋាភិបាលថា បានទាមទារឱ្យលោក កឹម សុខា ចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍មួយដែលលោកព្រួយបារម្ភខ្លាចទីបំផុតត្រូវបានប្រើប្រាស់ដើម្បីប្រឆាំងរូបលោក ដើម្បីទទួលបានការដោះលែងអ្នកទោស។

សកម្មជនម្នាក់ឈ្មោះ សុង ស្រីលាភ និយាយថា "យើងសោកស្តាយដែលសម្តេច ស ខេង បានអះអាងថា អ្នកការពារសិទ្ធិមនុស្សទាំងនោះ និងមន្ត្រី គ.ជ.ប. នឹងទទួលបានការដោះលែង។ ដូច្នេះយើងត្រូវចាប់ផ្តើមឡើងវិញបន្ទាប់ពីយើងបានទុកពេលឱ្យរដ្ឋាភិបាលពីរសប្តាហ៍"។

មន្ត្រីសិទ្ធិមនុស្ស និងមន្ត្រី គ.ជ.ប. ត្រូវបានចាប់ខ្លួនបញ្ជូនទៅពន្ធនាគារកាលពីខែមេសា បន្ទាប់ពីរងការចោទប្រកាន់ពីបទប៉ុនប៉ងសូកប៉ាន់ស្រីកំណាន់របស់លោក កឹម សុខា ដើម្បីឱ្យនាងបដិសេធស្នេហាលួចលាក់របស់ខ្លួននៅក្នុងសំណុំរឿងមួយដែលមជ្ឈដ្ឋានទូទៅចាត់ទុកថា ជារឿងនយោបាយ។



Activists demonstrate in the BoengKak community on Monday as part of a Black Monday protest calling for the release of prisoners. (Siv Channa/The Cambodia Daily)

កញ្ញា សុង ស្រីលាភ និយាយថា យុទ្ធនាការថ្ងៃច័ន្ទពណ៌ខ្មៅនឹងមិនបញ្ឈប់ឡើយ ប្រសិនបើក្រុមនេះមិនត្រូវបានដោះលែងរួមជាមួយអ្នកស្រី ទេព វន្នី ជាសកម្មជនដែលកំពុងជាប់ពន្ធនាគារនៅឡើយតាមបទចោទប្រកាន់ទាក់ទិនបាតុកម្មមួយកាលពីឆ្នាំ២០១១នោះទេ។

កញ្ញាបន្តថា "ទោះបីមានការសន្យា ឬការព្រមព្រៀងគ្នាក៏ដោយ ក៏យើងនឹងមិនផ្អាកយុទ្ធនាការថ្ងៃច័ន្ទពណ៌ខ្មៅដែរ ប្រសិនបើពួកគាត់គ្មានសេរីភាព"។

លោក សុខ ឥសាន អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាបានមានប្រសាសន៍ថា កិច្ចព្រមព្រៀងទាក់ទិនការដោះលែងមន្ត្រីសមាគមអាដហុក និងមន្ត្រីគ.ជ.ប. នៅតែមានឱកាសអាចសម្រេចតាមរយៈការចរចា ប៉ុន្តែបានអះអាងថា ចុងបញ្ចប់សេចក្តីសម្រេចស្ថិតក្នុងដៃតុលាការ។

លោកបានលើកឡើងទៀតថា "អ្វីដែលសម្តេច ស ខេង បានលើកឡើងកាលពីខែមុន គ្រាន់តែមានន័យថា នឹងមានការចរចាលុះត្រាមានជំនួបជាមួយលោក កឹម សុខា៕

**ភាគីទាំងពីរត្រូវគោរពនីតិវិធីតុលាការ"។**

**សុខុម**

# BLACK MONDAY STARTS AGAIN AS ADHOC OFFICERS LANGUISH IN JAIL

**by Sek Odom | January 10, 2017**

The long-running Black Monday campaign restarted on Monday in response to the continued imprisonment of four officers from rights group Adhoc and an election official, despite expectations of their release at the end of last year.

Protesters vowed to continue the campaign until the group is freed.

Hopes were raised early last month when it was reported that acting CNRP President KemSokha and Prime Minister Hun Sen had put the wheels in motion for the human rights officers and NyChakrya, an election official who previously worked for Adhoc, to leave prison after eight months in detention.

However, with the group still behind bars, about 20 activists staged a protest in Phnom Penh's eviction-hit BoengKak community on Monday morning. Unlike many previous protests, there was no scuffling with police and no arrests.

Mr. Sokha last week requested a meeting with Interior Minister Sar Kheng, who accepted, but did not set a date. CNRP President Sam Rainsy, meanwhile, this week accused the government of demanding that Mr. Sokha sign a statement-which the opposition leader fears will eventually be used against him-in order to secure the prisoners' release.

"We regret that Samdech Sar Kheng claimed those human rights defenders and [election] official would be released," activist Sung Sreyleap said.

"So, we have to start again," she added.

The human rights officers and election official were jailed in April after being accused of attempting to bribe an alleged mistress of Mr. Sokha to deny an affair, in a case generally considered to be politically motivated.

Ms. Sreyleap said the Black Monday campaign would not be halted unless the group is released along with fellow land activist TepVanny, who remains in jail on charges relating to a 2011 demonstration.

CPP spokesman SokEysan said an agreement over the release of the Adhoc officers and the election official could still be reached through negotiations, but claimed that the decision ultimately lay in the hands of the courts.

"What Samdech Sar Kheng raised last month just meant that there would be negotiations until there's a meeting with Mr. KemSokha," he said.

ហាងធ្វើក្រចកដ៏សម្បូរភ្ញៀវនឹង
សាឡុងជួលថ្លៃ $៥00/ខែ
ដូចគ្នានឹងមានហាងខ្លួនឯង
-ដុសខាតសំអាតក្រចក៣ នឹង តុ"ប៉េឌីគួរ"៣
-ថ្លៃទឹក-ភ្លើង រាប់បញ្ចូលហើយ
-ជ្រើសរើសបុគ្គលិកអ៊ុតសក់ និងធ្វើក្រចម
អស័យដ្ឋាន 933 Gorham St. Lowell, MA 01852
សូមទូរស័ព្ទរក ដាយ៉ាណា Diana 978-641 1455

KhmerPost USA

# Presidents of the U



1 **George Washington**
April 30, 1789-March3, 1797
Virginia

2 **John Adams**
March 4, 1797-March3, 1801
Massachusetts

3 **Thomas Jefferson**
March 4, 1801-March3, 1809
Virginia

4 **James Madison**
March 4, 1809-March3, 1817
Virginia

5 **James Monroe**
March 4, 1817-March3, 1825
Virginia

6 **John Quincy Adams**
March 4, 1825-March3, 182
Massachursetts



13 **Millard Fillmore**
July 9, 1850-March3, 1753
New York

14 **Franklin Pierce**
March 4, 1853-March3, 1757
New Hampshire

15 **James Buchanan**
March 4, 1857-March3, 1761
Pennsylvania

16 **Abraham Lincoln**
March 4, 1861-April 15, 1865
Illinois

17 **Andrew Johnson**
April 15, 1865-March 3, 1869
Tennessee

18 **Ulysses S. Grant**
March 4, 1869-March 3, 18
Illinois



25 **William Mckinley**
March 4, 1897-September 14, 1901
Ohio

26 **Theodore Roosevelt**
September 14, 1901-March 3, 1909
New York

27 **William H. Taft**
March 4, 1909-March 3, 1913
Ohio

28 **Thomas Woodrow Wilson**
March 4, 1913-March 3, 1921
New Jersey

29 **Warren Harding**
March 4, 1921-August 2, 1923
Ohio

30 **John Calvin Coolidg**
August 2, 1923-March 3, 1
Massachursetts



37 **Richard Nixon**
January 20, 1869-August 9, 1974
California

38 **Gerald Ford**
August 9, 1974-January 20, 1977
Michigan

39 **James Earl Carter**
January 20, 1977-January 20, 1981
Georgia

40 **Ronald Reagan**
January 20, 1981-January 20, 1989
California

41 **George H. W. Bush**
January 20, 1989-January 20, 1993
Texas

42 **William Jefferson Cli**
January 20, 1993-January 20
Arkansas

# nited States of America



7 **Andrew Jackson**
March 4, 1829-March3, 1837
Tennesee



8 **Martin Van Buren**
March 4, 1837-March3, 1841
New York



9 **William H. Harrison**
March 4, 1841-April 4, 1841
Ohio



10 **John Tyler**
April 4, 1841-April 3, 1845
Virginia



11 **Jmaes K. Polk**
April 4, 1845-March 3, 1849
Tennessee



12 **Zachary Taylor**
April 4, 1849-July 9, 1850
Louisiana



19 **Rutherford B. Hayes**
March 4, 1877-March 3, 1881
Ohio



20 **James Garfield**
March 4, 1881-Semtember 19, 1881
Ohio



21 **Chester A. Arthur**
Sept 19, 1881-March 3, 1885
New York



22 **Stephen Grover Cleveland**
March 4, 1885-March 3, 1889
New York



23 **Benjamin Harrison**
March 4, 1889-March 3, 1893
Indiana



24 **Stephen Grover Cleveland**
March 4, 1893-March 3, 1897
New York



31 **Herbert Hoover**
March 4, 1929-March 3, 1933
California



32 **Franklin D. Roosevelt**
March 4, 1933-April 12, 1945
New York



33 **HarryS. Truman**
April 12, 1945-January 20, 1953
Missouri



34 **Dwight D. Eisenhower**
April 12, 1945-January 20, 1961
New York



35 **John F. Kennedy**
January 20, 1961-November 22, 1963
Massachursetts



36 **Lyndon B. Johnson**
November 22, 1963-January 20, 1969
Texas



43 **George W. Bush**
January 20, 2001-January 20, 2009
Texas



44 Barack Obama
January 20, 2009-Current
Illinois



45 "Donald Trump
January 20th.2017"



"Donald and Melania Trump"

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ជំនឹងប្រែសំរួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# បុរសម្នាក់នៅខេត្តព្រៃវែងស្រមៃចង់សាកល្បង ហោះហើរយន្តហោះដែលខ្លួនច្នៃ

**ដោយ ប៊ុត គឹមសាយ | ថ្ងៃព្រហស្បតិ៍ ទី១២ ខែមករា ឆ្នាំ២០១៧**

ប៉ែន ឡុង នៅចាំបានពេលដែលលោកបានឃើញ "យន្តហោះ" នៅលើមេឃជាលើកដំបូង។

វាគឺនៅក្នុងឆ្នាំ១៩៩៣ ហើយលោក ប៉ែន ឡុង ដែលមានអាយុ៦ឆ្នាំនៅពេលនោះបានរត់ក្នុងចម្ងាយរាប់គីឡូម៉ែត្រដើម្បីឱ្យបានទៅដល់កន្លែងចុះចតនៅក្នុងខេត្តស្វាយរៀង។ នៅពេលលោកបានរត់ទៅដល់យន្តហោះនោះដែលតាមពិតគឺជាឧទ្ធម្ភាគចក្រហៀបនឹងហោះឡើងទៅហើយ។

លោកបាននិយាយកាលពីម្សិលមិញថា "ខ្ញុំស្រឡាញ់យន្តហោះតាំងពីខ្ញុំឃើញវាដំបូងម្ល៉េះ"។ ប៉ុន្តែ គឺប្រព័ន្ធដំណើរមេកានិកដែលធ្វើឱ្យគាត់ចាប់ចិត្តដិតអារម្មណ៍តាំងពីដើមទីមក ហើយការចាប់ចិត្តដិតអារម្មណ៍លើយន្តហោះនេះហើយដែលធ្វើឱ្យគាត់ចាប់យកការងារកម្សាន្តខុសប្លែកពីគេ គឺគាត់កំពុងបង្កើតយន្តហោះដោយខ្លួនឯង។

វាប្រហែលជាយានដ៏តូចល្មមមួយ ប៉ុន្តែវាដូចយន្តហោះអ៊ីចឹង។ វាមានបណ្តោយ៤,៣ម៉ែត្រ និងមានស្លាបប្រវែង៨ម៉ែត្រ។ វាមានកៅអីតែមួយប៉ុណ្ណោះសម្រាប់អ្នកបើកបរ។ តួនិងស្លាបយន្តហោះសុទ្ធតែធ្វើពីដែកធុងសាំង។

លោក ប៉ែន ឡុង បានលើកឡើងថា ប្រសិនបើអ្វីៗទាំងអស់នេះដំណើរការទៅមុខតាមការគ្រោងទុកមែនលោកអាចនឹងហោះហើរវាសាកល្បងជាលើកដំបូងនៅខែមេសា។

ប៉ុន្តែ វាគឺជាផ្លូវដ៏វែងឆ្ងាយសម្រាប់បុរសអាយុ៣០ឆ្នាំរូបនេះដែលប្រកបរបរចិញ្ចឹមជីវិតដោយធ្វើជាជាងមេកានិករថយន្តនៅក្នុងភូមិព្រៃឈរ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ លោក ប៉ែន ឡុង បាននិយាយថា "បន្ទាប់ពីខ្ញុំធ្វើយន្តហោះនេះបានប្រហែល២០ភាគរយ ខ្ញុំស្ទើរតែបោះបង់ចោលទៅហើយ"។ លោកបានបន្ថែមថា ដោយសារធនធានមានកំណត់ការស្វែងរកសម្ភារ និងព័ត៌មានពាក់ព័ន្ធបច្ចេកវិទ្យាដើម្បីធ្វើឱ្យវាក្លាយជាទៅជាយន្តហោះនោះ មិនមែនជារឿងងាយស្រួលនោះទេ ប៉ុន្តែលោកនៅតែបន្តទៅមុខ។

មានពេលមួយគាត់បានជួបការលំបាកយ៉ាងខ្លាំងពាក់ព័ន្ធបញ្ហាបច្ចេកទេសដែលធ្វើឱ្យគាត់មិនអាចជម្នះទៅមុខបានឡើយបើរកមិនបានគ្រឿងមេកានិកសំខាន់ៗ។ ប៉ុន្តែគាត់បានលើកឡើងថាគាត់បានរកឃើញវានៅកន្លែងដែលគេទុកយន្តហោះចោលតាមបណ្តោយផ្លូវជាតិលេខ៣។

ដោយរៀបការរួចហើយនិងមានកូនពីរនាក់នោះ លោក ប៉ែន ឡុង បានជួបការលំបាកយ៉ាងខ្លាំងក្នុងការការស្វែងរកប្រាក់សម្រាប់គម្រោងនេះ។ តែទោះជាយ៉ាងណារហូតមកទល់ពេលនេះ គាត់អាចរកប្រាក់បានពាក់កណ្តាលហើយនៃប្រាក់ដែលត្រូវការចំនួន១០.០០០ដុល្លារ។



លោក ប៉ែន ឡុង អង្គុយនៅក្នុងយន្តហោះដែលលោកកែច្នៃដោយខ្លួនឯងនៅផ្ទះរបស់លោកក្នុងខេត្តព្រៃវែង។ ប្រសិនបើអ្វីៗដំណើរការតាមការគ្រោងទុកលោកនឹងហោះហើរវាសាកល្បងនៅខែមេសា។ រូបថតៈ ប៉ែន ឡុង

គម្រោងរបស់លោក ប៉ែន ឡុង នេះបានធ្វើឱ្យប្រជាពលរដ្ឋមួយចំនួននៅក្នុងភូមិរបស់លោកព្រួយបារម្ភយ៉ាងខ្លាំងដោយចាប់ផ្តើមចេញពីប្រពន្ធរបស់គាត់ គឺអ្នកស្រី ហ៊ីង មួយហេង តែម្តង។ ទោះជាយ៉ាងណាការព្រួយបារម្ភរបស់ប្រពន្ធគាត់មិនមែនរឿងពេលវេលា ឬរឿងប្រាក់ដែលប្តីរបស់គាត់បានចំណាយនោះឡើយ ប៉ុន្តែគឺរឿងសុវត្ថិភាពរបស់គាត់ផ្ទាល់តែម្តងពេលលោកទីបំផុតព្យាយាមបើកសាកល្បងយន្តហោះនេះជាលើកដំបូង។

អ្នកស្រីបាននិយាយថា "ខ្ញុំបានសុំឱ្យប្តីរបស់ខ្ញុំបញ្ឈប់ជាច្រើនលើកមកហើយ ប៉ុន្តែគាត់ចង់បង្ហាញថា គាត់ពិតជាអាចធ្វើបាន។ ឥឡូវនេះខ្ញុំជឿជាក់លើគម្រោងរបស់គាត់"។

អ្នកជិតខាងរបស់លោក ប៉ែន ឡុង គឺអ្នកស្រី លឹម សេង ដំបូងឡើយមិនជឿថាយន្តហោះរបស់បុរសរូបនេះអាចហោះហើរបាននោះឡើយ។ អ្នកស្រី លឹម សេង បាននិយាយថា "ខ្ញុំសួរគាត់ថា តើវាអាចហោះហើរបានមែនអត់ ហើយគាត់បានប្រាប់ខ្ញុំថា ប្រសិនបើមានការអត់ធ្មត់រាល់គម្រោងនឹងមានដំណើរការទៅមុខ ហើយគាត់ជឿជាក់ថា វានឹងដំណើរការទៅមុខ"។ អ្នកស្រីបានបន្ថែមថា "ឥឡូវវាជិតជោគជ័យហើយ ហើយវាប្រហែលហោះហើរបានល្អ"។

តទៅទំព័រទី ១៨

# MAN DREAMS OF FLIGHT WITH AIRPLANE BUILT FROM SCRATCH, SCRAP

**by ButhKimsay | January 12, 2017**

Paen Long still recalls the first time he saw an "airplane" in the sky.

It was 1993 and Mr. Long, who was 6 at the time, ran for kilometers to get to the landing site in SvayRieng province. By the time he reached the aircraft, which was actually a helicopter, it was ready to take off.

"I have loved planes ever since that first time," he said on Wednesday. But from the start, it was the mechanical workings that fascinated him, and that keen interest in flight has led him to take up a very unusual hobby: He is building his own airplane.

A modest vehicle, perhaps, but a plane all the same. It is 4.3 meters long and has an 8-meter wingspan. There is only one seat, for the pilot-a plastic chair with the legs sawn off. The body and wings are made of metal from gasoline cans.

If all goes according to plan, Mr. Long should be able to take it for its first flight in April, he said.

But it's been a long road for the 30-year-old, who earns his living as a car mechanic in KompongTrabek district's Prey Chhor commune, in Prey Veng province. "After I completed about 20 percent of the plane, I almost gave up," Mr. Long said.

With his limited resources, finding the materials and technical information to make it happen was far from easy, he said.

But he kept going.

At one point, he was mired in technical difficulties, which he could not overcome without finding specific mechanical parts. But he located them, he said, at a junk airplane site along National Road 3.

Married with two young children, Mr. Long has struggled to raise the funds for the project. Still, he has so far managed to raise half of the required $10,000.

His project has left some people in his neighborhood scratching their heads-starting with his wife, Hing Mouy Heng. Her concern, however, is not about the time or money her husband spent on his obsession, but about his safety when he eventually tries to take his plane into the air.



Paen Long's self-built airplane at his home in Prey Veng province (Paen Long)

"I asked my husband to stop several times, but he really wanted to prove that he could make it. Now, I believe in his plan," she said.

His neighbor, Lim Seng, at first doubted that Mr. Long's plane would ever take off. "I asked him if it would fly and he told me that every project must start somewhere and that he trusted it would work," Ms. Seng recalled. "Now it's getting close to success, and it may very well fly."

Prey Chhor commune chief SekKheang has always been enthusiastic about Mr. Long's plane, saying someone from his commune attempting something that new and different deserved his support. "I don't know whether this plane will be able to fly, but we'll have to wait and see," he said.

In the past few weeks, Mr. Long's project has made it onto social media, and Prey Veng governor Chea Somethy paid him a visit on Wednesday afternoon.

A word of caution, however, came on Wednesday from Keo Sivorn, a spokesman for Civil Aviation. While it is a wonderful project that should be encouraged, Mr. Long should have his plane checked by an expert before attempting his first flight for his own safety, he said.

And, just in case, he added, Mr. Long should try not to take off too close to other planes on his inaugural flight.

kimsay@cambodiadaily.com

# ទស្សនាព្រះសក្យមុនីចេតិយនៅលើកំពូលភ្នំឧដុង្គ

**ដោយ ពិន ពិទូ**

ភ្នំឧដុង្គគឺជារមណីយដ្ឋានប្រវត្តិសាស្ត្រ និងជាសម្បត្តិបេតិកភណ្ឌជាតិដ៏អស្ចារ្យ ។ ភ្នំនេះមានឈ្មោះបី គឺភ្នំឧដុង្គ ភ្នំព្រះរាជទ្រព្យ និងភ្នំអដ្ឋរស្ស។ ភ្នំឧដុង្គជាអតីតរាជវាំងនៃក្រុងឧដុង្គមានជ័យ នាសតវត្សទី១៧ ពីឆ្នាំ១៦១៨ ដល់ឆ្នាំ១៨៦៦) ហើយត្រូវបោះបង់ដោយព្រះបាទនរោត្តមនៅឆ្នាំ១៨៦៦ ដោយផ្លាស់មករាជធានីភ្នំពេញមកទល់សព្វថ្ងៃ។ ចំណុចពិសេសនៃភ្នំនេះមានរូបរាងវែងដូចសត្វមករនាគ) ។ ភ្នំនេះជាកន្លែងបញ្ចុះសពរបស់ព្រះរាជវង្សានុវង្សនិងជាកន្លែងដែលអតីតព្រះមហាក្សត្ររាជានុញ្ញាតិឱ្យសាងសង់វត្តនិងព្រះវិហារទ្រង់បានត្រាស់ឱ្យសាងសង់ព្រះចេតិយធំៗ និងមានចម្លាក់លំអរសំរាប់បញ្ចុះព្រះបរមអដ្ឋិ និងព្រះអដ្ឋិនៃព្រះរាជវង្សានុវង្ស។ ក្រៅពីចេតិយអតីតព្រះមហាក្សត្រ ក៏មានកន្លែងបូជនីយដ្ឋាន ជាច្រើនកន្លែងទៀតដូចជាព្រះវិហារនៃវត្តព្រះធម៌កេរ្តិ៍ក្នុងនោះមានព្រះពុទ្ធប្បដិមាយ៉ាងធំក្រៃលែងខ្ពស់ដល់ដំបូលព្រះវិហារដែលមានកំពស់១៨ហត្ថ និងមានរឿងដំណាលបានកត់ត្រាក្នុងប្រវត្តិសាស្ត្រទាក់ទងនឹងព្រះពុទ្ធប្បដិមាដ៏ធំនេះដែរ ។ នៅលើកំពូលភ្នំខ្ពស់ជ្រុងខាងជើង គឺជាព្រះសក្យមុនីចេតិយមានក្បូរក្បាច់រចនាយ៉ាងស្រស់ស្អាតសំរាប់តម្កល់ព្រះសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធជាបរមគ្រូនៃយើងអតីតព្រះមហាក្សត្រព្រះបរមកោដ្ឋបានសព្វព្រះរាជហរទ័យយាងដង្ហែរព្រះចង្កូមកែវទៅតម្កល់ក្នុងព្រះសក្យមុនីចេតិយនៅលើកំពូលភ្នំនេះកាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០២ ដើម្បីពុទ្ធបរិស័ទគោរពបូជា។ ចំណែកផ្នែកខាងក្រោមនៃព្រះសក្យមុនីចេតិយមានតំកល់ព្រះពុទ្ធប្បដិមាចំនួន៥៣៣៤អង្គ គង់លើបល្លង្គយ៉ាងស្រស់ស្អាត ។

ភ្នំឧដុង្គនេះស្ថិតក្នុងឃុំផ្សារដែក និងឃុំភ្នំបាតស្រុកពញាឮខេត្តកណ្ដាលធ្វើដំណើរចេញពីរាជធានីភ្នំពេញតាមបណ្ដោយផ្លូវជាតិលេខប្រាំដែលមានចំងាយ៤០គីឡូម៉ែត្រនៅភាគពាយព្យនៃទីក្រុងភ្នំពេញឆ្លងកាត់ស្ពានព្រែកក្ដៅដ៏ស្រស់ស្អាតព្រមទាំងទេសភាពដ៏ត្រកាល និងខ្យល់ត្រសៀកៗគួរជាទីមនោរម្យយើងបានបើកបរនៅលើផ្លូវក្រាលកៅស៊ូទូលាយល្មមដែលមិនសូវមានឡានម៉ូតូកកស្ទះដូចនៅរាជធានីភ្នំពេញឡើយហើយមានផ្ទះអ្នកស្រុកនៅហែរហមតាមផ្លូវនិងមានលក់ដូរខ្លះៗ ដូចជាលក់ពោតសោរបន្លែ និងផ្លែឈើនៅលើតូបតាមចិញ្ចើមផ្លូវយើងបានមើលឃើញទិដ្ឋភាពវាលស្រែដ៏ស្រស់ត្រកាល និងឆ្នេរទន្លេរដ៏វែងអន្លាយតាមបណ្ដោយផ្លូវជាតិមិនយូរប៉ុន្មានពួកយើងក៏មកដល់ក្លោងទ្វារនៃច្រកផ្លូវចូលធ្វើពីស៊ីម៉ង់ដែលនៅខាងលើមានឆ្លាក់អក្សរពុម្ពធំៗគឺព្រះសក្យមុនីចេតិយ និងទង់ជាតិព្រះពុទ្ធសាសនាអមសងខាងផ្លូវចូលទៅកាន់រមណីយដ្ឋានភ្នំព្រះរាជទ្រព្យ ប្រហែលជាង១គីឡូម៉ែត្រទៀត នៅតាមផ្លូវលំ នេះមានផ្ទះអ្នកស្រុកតិចតួចនៅបណ្ដាក់គ្នា និងមានបឹងបួរទឹកថ្លាឆ្វង់ព្រមទាំងខ្យល់អាកាស





ដ៏បរិសុទ្ធ ព្រោះទីនេះមិនមានឡានម៉ូតូ ឬរោងចក្របំពុលបរិស្ថានឡើយ ។ មកដល់ជើងភ្នំព្រះរាជទ្រព្យមានថមួយផ្ទាំងធំឆ្លាក់អក្សរថា "ពុទ្ធមណ្ឌលវិបស្សនាធុរៈនៃព្រះរាជាណាចក្រកម្ពុជា"



"VIPASSANA DHURA BUDDHIST CENTRE OF KINGDOM OF CAMBODIA" ។ យើងបានដើរឡើងតាមជណ្ដើរថ្មដ៏ស្អាតឆ្ពោះទៅខាងលើកំពូលភ្នំដល់ពាក់កណ្ដាលឃើញមានអាស្រមមួយដែលមានព្រះពុទ្ធប្បដិមាសំរាប់អ្នកទស្សនាថ្វាយផ្កា ទានធូប ឧទ្ទិសបូជាដល់ព្រះសម្មាសម្ពុទ្ធ និងប្រាថ្នាសុំសេចក្ដីសុខ។ ឡើងជណ្ដើរទៅខាងលើបន្តទៀតមកដល់ព្រះវិហារយ៉ាងធំទូលាយដែលមានព្រះពុទ្ធប្បដិមាយ៉ាងធំសម្បើមដែលកំរជួបប្រទះ គឺព្រះវិហារវត្តព្រះធម៌កេរ្តិ៍ លោកអាចារ្យមុតដែលកំពុង

អង្គុយនៅខាងក្នុងព្រះវិហារជាមួយនឹងគម្ពីរទស្សទាយពីជោគជតារាសីនៅខាងមុខបានរៀបរាប់ពីដំណើររឿងថា អតីតព្រះមហាក្សត្របានបញ្ជាឱ្យកសាងវត្តនេះឡើងឱ្យព្រះចៅអធិការវត្តជាអ្នកថែរក្សាសម្បត្តិទ្រព្យនៅលើខ្នងភ្នំព្រះរាជទ្រព្យនេះដែលរួមមានចេតិយតូច និងចេតិយធំរបស់អតីតព្រះមហាក្សត្រជាដើម ចំណែកឯព្រៃឈើលោកមិនអាចថែរក្សាបាន ក៏បង្កើតមេព្រៃជាអ្នកថែរក្សាព្រៃឈើជំនួសអតីតព្រះមហាក្សត្រក៏បានបញ្ជាឱ្យសាងសង់ស្រះទឹកទុកជាសម្បត្តិរបស់វត្តព្រះធម៌កេរ្តិ៍នេះដែរ ស្រះនេះនៅរក្សាមកទល់សព្វថ្ងៃ ចំណែកឯព្រះវិហារនៃវត្តធម៌កេរ្តិ៍នេះ គឺបានសាងសង់ដោយអតីតស្ដេចចិនដោយហេតុថាស្ដេចខ្មែរយើងមិនបានដឹងថា នៅលើខ្នងភ្នំព្រះរាជទ្រព្យនេះមានបារមីរូបសត្វនាគមករដែលជាបារមីមានមហិទ្ធិរិទ្ធខ្លាំងក្លាក្រៃលែងបើសិននាគមករនេះងើបឡើងប្រទេសកម្ពុជានឹងក្លាយជាប្រទេសមហាអំណាចខ្លាំងក្លាលើសបណ្ដាប្រទេសផ្សេងទៀត អតីតស្ដេចចិនបានដឹង ដូចច្នេះក៏ត្រិះរិះថាតើត្រូវធ្វើដូចម្ដេចកុំឱ្យប្រទេសខ្មែរមានអំណាចខ្លាំងក្លាលើសគេ ដោយសង្កេតឃើញខ្មែរយើងកាន់ព្រះពុទ្ធសាសនាចិនក៏បានបញ្ជាឱ្យនាម៉ឺនមកក្រាបសំពះសុំព្រះមហាក្សត្រខ្មែរសាងសង់រូបព្រះពុទ្ធប្បដិមាដ៏ធំនេះឡើង ដើម្បីសន្ទប់គ្រប



ពីលើរន្ធរបស់នាគកុំឱ្យងើបរួច បន្ទាប់ពីសាងសង់ព្រះវិហារ និងរូបព្រះពុទ្ធប្បដិមាយ៉ាងធំនេះរួចរាល់ចិនក៏ប្រគល់ជូនខ្មែរយើងវិញ ដើម្បីទុកជាទីសក្ការៈបូជាក្រោយមកទៀតទើបស្ដេចខ្មែរបានដឹងពីរឿងនេះ ប៉ុន្តែមិនអាចធ្វើអ្វីកើតព្រោះរូបព្រះសម្មាសម្ពុទ្ធមិនអាចប៉ះពាល់បាននោះឡើយ កុំថាឡើយធំស្កឹមស្កៃដូចនេះ ទោះបីជារូបតូចប៉ុនធូបដែលបានឆ្លាក់ជាតួអង្គព្រះសម្មាសម្ពុទ្ធជាម្ចាស់ហើយ មិនអាចរំលាយបានទេ បើរំលាយ ដូចពាក្យស្លោកថាប្រមាថម្ដាយរំលាយព្រះមានទោសធន់ធរណាស់ទើបមិនហ៊ានប៉ះពាល់មកទល់សព្វថ្ងៃនេះ។ លោកតាអាចារ្យបានមានប្រសាសន៍បន្តថា មានថ្ងៃមួយមានគ្រួសារមួយបានយករូបសំណាកនាគរាជមកផ្ញើរលោកតា ព្រោះសត្វនាគនោះបានពន្យល់សប្តិគ្រួសារនោះឱ្យនាំយករូបសំណាករបស់ខ្លួនមកកាន់កន្លែងដើមវិញ។ លុះក្រោយមកគ្រួសារនោះក៏បាននាំយករូបនាគមកផ្ញើរលោកតា ព្រោះពួកគេយល់ថាទីកន្លែងនេះសាកសមបំផុត ហើយលោកតាក៏បានរក្សាទុកមកទល់សព្វថ្ងៃនេះ ដោយចាក់សោរទុកត្រឹមត្រូវ ទោះបីមានលោកសង្ឃ ឬអ្នកណាម្នាក់ចង់បានរូបនាគនោះដោយឱ្យលុយប៉ុន្មានក៏លោកតាមិនលក់ដាច់ខាត។ យោងតាមឯកសារស្ដីពី" សវតារវត្ត អដ្ឋរស្ស ដែលអ្នកអង្គម្ចាស់ក្សត្រីយ៍នរោត្តម សុខានារី បានរៀបរៀងទុកមានខ្លឹមសារសង្ខេបថា នៅអំឡុងសតវត្សរ៍ទី១៣នៃគ្រីស្ដសករាជព្រះចៅក្រុងចិនបានចាត់ឱ្យបេសកជនជាច្រើនក្រុមឱ្យមកចូលទស្សនកិច្ច និងសិក្សាជកបទពិសោធន៍អំពីអរិយធម៌របស់ប្រទេសជិតខាងក្នុងនោះមានប្រទេសកម្ពុជាយើងផងដែរ។ នៅឆ្នាំ១២៩៥ មានបេសកជនចិនម្នាក់ឈ្មោះជីវតាក្វាន់បានចូលមកកត់ត្រាអំពីទំនៀមទំលាប់ និងវប្បធម៌របស់ជនជាតិខ្មែរនៅសម័យអង្គរ។ បន្ទាប់មកក៏បានទូលថ្វាយទៅស្ដេចចិនវិញថា ប្រទេសខ្មែរជាប្រទេសថ្កុំថ្កើងរុងរឿងមាន ឬទ្ធានុភាពមិនយូរប៉ុន្មានខ្មែរមុខជាប្រសព្វនឹងសេចក្ដីថ្កុំថ្កើងរុងរឿងឡើងវិញ លើសដើមយ៉ាងអស្ចារ្យ។ ពីព្រោះបេសកជនចិនបានសម្គាល់ឃើញតាមក្បួនចិនសែដែលទស្សទាយអំពីចំណុចនៃភ្នំព្រះរាជទ្រព្យក្នុងស្រុកឧដុង្គនូវទម្រង់ភ្នំដូចសត្វមករដែលមានតួខ្លួននៅត្រង់ចេតិយស្ថានត្រៃត្រឹងក្បាល និងពុកមាត់នៅត្រង់ចេតិយទន្ទឹមរីឯកន្ទុយនៅត្រង់ព្រះពុទ្ធប្បដិមាចូលនិព្វាន។ នៅលើកំពូលភ្នំមានរូងមួយធំជ្រៅស្រឡូង ចុះក្រោមដែលបេសកជនចិនយល់ថា មិនយូរប៉ុន្មានសត្វមករនឹងកម្រើកចេញតាមរូងនេះ ហើយក្បួនចិនសែថា ពេលសត្វនេះផុសឡើងកាលណាប្រទេសខ្មែរនឹងមានអំណាចខ្លាំងក្លា និងថ្កុំថ្កើងរុងរឿងអស្ចារ្យពុំមានប្រទេសណាប្រៀបស្មើបាន។ ការព្យាករណ៍របស់ចិនសែនេះបណ្ដាលឱ្យនាម៉ឺន និងស្ដេចចិនមិនសប្បាយចិត្តក៏រកមធ្យោបាយសន្ទប់រន្ធឱ្យជិតកុំឱ្យសត្វមករផុសឡើងកណ្ដាលខ្នងភ្នំ។ ពួកចិនគិតទៀតថា មានតែសង់វិហារតម្កល់ព្រះពុទ្ធប្បដិមាឱ្យធំនៅទីនោះ ព្រោះ

តទៅទំព័រទី២០

# លោក ស ខេង យល់ស្របតាមរបាយប៉ូលិសនៅប៉ោយប៉ែត


លីម គិមយ៉ា

ក្រោយពីអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យចេញសេចក្តីសន្និដ្ឋានបឋមកាលពីថ្ងៃអង្គារ ទី២៧ ខែធ្នូ ថានាយរងប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែតលោក ឈាន ពិសិដ្ឋ ពិតជារងរបួសនៅជើងស្តាំរហូតដួលសន្លប់ដោយសារលោក ឌិន ពុទ្ធីមន្ត្រីរបស់គណបក្សប្រឆាំងបើករថយន្តបុកតាមរបាយការណ៍បូលិសមកលោករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេងបានយល់ស្របកាលពីថ្ងៃទី២ ខែមករា ឆ្នាំ២០១៧ពីការសន្និដ្ឋានរបស់អយ្យការសាលាដំបូងខេត្តបន្ទាយមានជ័យដោយថា : "ពិនិត្យអស់ហើយជុំវិញរឿងនេះពិត គឺវាអ៊ីចឹង ព្រោះអ្វីដែលព្រះរាជអាជ្ញាសាលាដំបូងខេត្តបន្ទាយមានជ័យគេបានដំណើរការ"។ បានសេចក្តីថា លោក ស ខេង អត់បានចាត់ឱ្យមានការអង្កេតឯករាជណាមួយទេ គឺគ្រាន់តែនិយាយតាមការសន្និដ្ឋានរបស់អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យតែប៉ុណ្ណោះ ។

តើអយ្យការនេះបានហៅសាក្សីទៅសួរ ឬអត់ តើបានមើលវិដេអូដែលគេបង្ហោះជាច្រើនជាពិសេសវិដេអូចុងក្រោយបង្ហាញលោក ឈាន ពិសិដ្ឋ ដើរចេញនៅសណ្ឋាគានៅស្រុកសៀមជាមួយស្រីម្នាក់ដូចជាគ្មានរបួសអ្វីទាំងអស់ ។ សញ្ញាទាំងអស់នេះ បើប្រសិនណាជាអយ្យការមានគតិយុទ្ធ គឺត្រូវហៅលោក ឈាន ពិសិដ្ឋមកសួរ ព្រោះកាលពេល "សន្លប់" ថា សួរមិនបាន ហើយត្រូវឱ្យពេទ្យផ្សេងទៀត ធ្វើបដិកោសលវិច័យដែលពេទ្យមុនមើលនោះ ជាពិសេសរូបថតករ ដែលថាក្រិច ។ តែនេះអត់មានទេ មានអ្នកឃើញជាច្រើនបានស្ម័គ្រចិត្តនាំគ្នាទៅឈរបង្ហាញមុខ និងសុំចូលទៅធ្វើជាសាក្សី ក៏តុលាកាមិនហៅទៅទេ នេះគឺបានសេចក្តីថា អយ្យការនេះបានសន្និដ្ឋាន ដូចជាគ្រោងទុកជាមុនមិនចាំបាច់ចុះទៅស៊ើបសួរទេ ។

នេះយើងមិនឆ្ងល់ទេ ដូចជាអយ្យការអមសាលាដំបូងរាជធានីភ្នំពេញមានការឆកល្បែងយ៉ាងដូច្នេះដែរ កាលពីមានការវាយទាប់គ្នាកាលពីថ្ងៃទី ១៥ កក្កដា ឆ្នាំ ២០១៤ រវាងអ្នកហែបាតុកម្មនឹងកងកំលាំងជួលដោយសាលាខ័ណ្ឌដូនពេញ គង់តែមានវិដែអូជាភស្តុតាងយ៉ាងដូចម្តេចក៏ដោយក៏អយ្យការនេះ សន្និដ្ឋានថា ពួកបាតុករជាអ្នកបង្កហេតុ ហើយចាប់ដាក់គុកដោយខ្លះ ទោសដល់ទៅជាង១០ឆ្នាំទៅទៀត ។

ដូចជារឿងសំលាប់លោក កែម ឡី ក៏ដូច្នេះដែរ គឺចៅក្រមស៊ើបអង្កេតសន្មត់កាលពីថ្ងៃទី ២៣ ធ្នូ ថា មានតែមនុស្សមួយម្នាក់ឈ្មោះ ពិត អឿត អាងហៅ "ជួបសំលាប់"។ ហើយចៅក្រមស៊ើបអង្កេតមិនព្រមបង្ហាញវិដេអូឱ្យសាធារណៈជនឱ្យឃើញ ព្រមទាំងនៅពេលនោះមានបុគ្គលិក ហាងសាំងកាលតិក (Caltex) ដែលឃើញជាសាក្សីក៏មិនបញ្ចេញកំណត់ហេតុនោះទេ ។ ចៅក្រមស៊ើបសួរបានបញ្ជូនសំណុំរឿងទាំងមូលទៅព្រះរាជអាជ្ញាដើម្បីធ្វើដីកាសន្និដ្ឋានស្ថាពរគង់តែមន្ត្រីនាំពាក្យក្រសួងមហាផ្ទៃលោក ខៀវ សុភ័គឱ្យដឹងនៅថ្ងៃទី២១ ធ្នូ ថា ក្រោយពីការសួរចម្លើយ និងការសារភាពរបស់ជនសង្ស័យជួបសម្លាប់លោកមិនជឿថាចម្លើយសារភាពជាការពិតទេ: "យើងបានសន្និដ្ឋានថា ជនល្មើសនេះមានចេតនាឆ្លើយបំភ័ន្តសមត្ថកិច្ចមិននិយាយការពិត។ យើងមិនជឿថាជនល្មើសនេះឈ្មោះ ជួប សម្លាប់ មិនជឿថា ជនល្មើសនេះឱ្យលុយ កែម ឡី ខ្ចី៣ពាន់។ លោកលោក ខៀវ សុភ័គ បន្ថែម: យើងមើលទី១ជួប សម្លាប់ វាមិនដែលខ្មែរយើងអ្នកណាឈ្មោះ ជួប សម្លាប់ទេ អាសម្លាប់ អាងាប់ទេ ។ទី២កែម ឡីជំពាក់លុយគេ៣ពាន់គឺអត់មានសោះ។ ទី៣ឈ្មោះ អាលីសលក់កាំភ្លើងឱ្យវាថា តម្លៃ៣ពាន់ដុល្លារដែរ ហើយថាឈ្មោះប៉ូលិសនៅថៃទៅរកឯណាឃើញ? មិនប្រាប់ទីកន្លែង"។

អំពើទាំងអស់នេះ ដែលគ្មានភាពប្រក្រតីតើឱ្យមតិមហាជននឹងអាចជឿទៅលើក្រសួងយុត្តិធម៌បានទេ ។ មិនត្រឹមតែប៉ុណ្ណោះអាជ្ញាធរបានកំញើញរិះរកនិតិវិធីតាមផ្លូវច្បាប់ ថានឹងប្តឹងចំពោះជនណាមួយដែលនិយាយខុសពីការសន្និដ្ឋានរបស់អាជ្ញាធរ ។

នេះមិនមែនតែការកំញើញនោះទេ មានទាំងច្បាប់ដែលអនុម័តនៅសភា កាលពីថ្ងៃទី ៣០ ខែវិច្ឆកា ឆ្នាំ ២០១៥ ច្បាប់ស្តីពីស្ថិតិ ដែលមានចែងថា ទិន្នន័យទាំងឡាយដែលចេញពីអាជ្ញាធ គឺជាទិន្នន័យផ្លូវការណ៍ហេតុនេះអ្នកណាមួយឱ្យឬនិយាយខុសពីទិន្នន័យនេះ គេអាចចោទបានពីនេះពីនោះ ដូចយើងឃើញស្រាប់មកហើយ ។

នេះ យើងរស់នៅក្នុងប្រទេសមួយដែលមិនដឹងយកអ្វីជាគោលនោះទេ ។ ពួកអ្នកកាន់អំណាចសព្វថ្ងៃស្មានតែខ្លួនកាន់អំណាចរហូតបានជាមិនគិតដល់ពេលធ្លាក់ពីអំណាចនោះទេ។ បើចេះគិតប្រហែលជាមុននឹងធ្វើអ្វីមួយត្រូវគិតពីផលវិបាកចំពោះអំពើរបស់ខ្លួន ។ហេតុនេះ យើងចេះតែចោទសួរថា បើពួកនេះធ្លាក់ពីអំណាចទៅតើពួកកូនចៅមិត្តភ័ត្ររត់ទៅរស់នៅឯណា? គង់តែអ្នកកាន់អំណាចថ្មីមិនប្រកាន់វប្បធម៌ទឹកឡើងត្រីស៊ីស្រមោចទឹកហោចស្រមោចស៊ីត្រីក៏ដោយតែអ្នកដែលរងគ្រោះដោយអំពើអយុត្តិធម៌អស់នេះ តើគេនឹងអនុគ្រោះឱ្យទេ ។

ទីបញ្ចប់ខ្ញុំសុំជូនយោបល់សើចលេងមួយបើប្រសិនណាមួយជាមានករណីយរបៀបនាយរងប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត លោក ឈាន ពិសិដ្ឋ ដែលធ្វើពុតដេកដួលមុខឡានរបៀបនេះ គឺយកទឹកចាក់ក្នុងច្រមុះឱ្យភ្ញាក់ ឬចាក់ម្រេចក្នុងច្រមុះឱ្យកន្តាស់ តើសន្លប់មែនឬអត់យើងត្រូវរកវិធីដេញដើងអ្នកខូច បើអាជ្ញាធរគ្មានយុត្តិធម៌ដូចនៅព្រះរាជាណាចក្រកម្ពុជានោះទេ ៕

**លិម គិមយ៉ា តំណាងរាស្រ្តគណបក្សសង្គ្រោះជាតិខេត្តកំពង់ធំ**

## Sheriff Koutoujian announces upcoming Correction Officer exam
## Registration open until February 13

BILLERICA, Mass. - Are you interested in a career with one of the nation's oldest law enforcement agencies?

The Middlesex Sheriff's Office - this year celebrating its 325th anniversary - is now accepting registrations for the upcoming Correction Officer exam. Registration is open until 1 p.m. on Monday, February 13, 2017 and there is no charge for the exam.

"This is an exciting time for the Middlesex Sheriff's Office and we are seeking qualified, motivated men and women interested in careers in corrections for our 41st Basic Training Academy," said Sheriff Peter J. Koutoujian.

Applicants must be 19 years of age, a U.S. citizen and a resident of Massachusetts by the date of the exam. You must also have a high school degree or equivalent certificate and possess a valid motor vehicle license. A Bachelor's degree and/or prior experience in law enforcement or security is preferred.

The exam will be administered on Saturday, February 18, 2017 at UMass Lowell.

To read a full list of qualifications and register for the exam please visit: www.middlesexsheriff.org.

For information Call: Kevin Maccioli **781-960-2805**



## Building Democracy in Cambodia

**University Massachusetts of Lowell (UML)**
**Monday, January 30, 2017, 3:30 p.m. - 6:20 p.m.**
**200 Coburn Hall, South Campus.**

### Executive Summary:

The Democratic Building Process in Cambodia is one of the most challenges of journey to endure in this world. Prince Thomico Sisowath will share his knowledges on what's a true democracy, its principles and its traits. He will share his insights and experiences by exploring the historical, political and cultural events of Cambodian society. These include the effect of 40 years of civil strive, Cambodian Genocide 1975-1979, Paris Peace Agreement in1993, United Nations Transitional Authority in Cambodia (UNTAC) sponsored the First National Democratic Election in Cambodia in1993, as well as the current Cambodian development programs. These events have shaped the Current Democratic Building Process in the Kingdom of Cambodia. Prince, also will share his perspectives about upcoming Cambodian Elections (Local Election/Commune Election in 2017 and National Election in 2018).

Do not miss this interesting and enriching presentation!

### Prince Thomico Sisowath's Brief Biography:

The Prince Thomico is a royal family member, was a Private Assistant to Former Cambodian King Norodom Sihanouk. Currently, he is one of the Steering Committee Members of Cambodian National Rescue Party (CNRP) which figures as the main opposition Party in Cambodia. The Prince studied Software Engineering at Ecole Des Arts et Metiers (CNAM) in Paris France. He also studied Political Science at Sciences-PO, Paris, France.

Prince has contributed in the numbers of publications which include: "Cambodia in the Conflict of Blocks: A Regional Perspective" ASEMI, Paris France; "Prince Sihanouk and the Khmer Fractions," Indochina Report, Singapore; as well as "Cambodia: The International Management of Genocide," Ankakota, Paris France. Prince Thomico Sisowath is married and has six children and currently lives in Cambodia.

# CENTURY PHARMACY & OPTICAL

937 Gorham St ALL MAJOR INSURANCES ACCEPTED Tel: 978-455-6554

យើងជាឱសថស្ថានមួយដែលអាចផ្ដល់ភាពជឿជាក់ដល់គ្រួសារលោកអ្នក




យើងខ្ញុំសូមជូនពរមហាប្រសើរដល់លោកអ្នក

- យើងខ្ញុំមានផ្ដល់សេវ៉ាបំរើការជូនឱសថដល់ទីលំនៅ ។
- យើងខ្ញុំទទួលកាតម៉ាសហ៊ែល, និងកាតធានារ៉ាប់រងសុខភាពផ្សេងៗទៀត
- សេវ៉ាបំរើការល្អ,អតិថិជនមានភាពជឿជាក់ ។
- យកចិត្តទុកដាក់លើបញ្ហាផ្ទាល់ខ្លួននៃអតិថិជនរាល់រូប ។
- វេចខ្ចប់ឱសថសមតាមបំណងនៃអតិថិជន ។
- មានផលិតកម្មពិសេសរបស់អូធីស៊ីជារៀងរាល់ខែ ។
- យើងខ្ញុំទទួលការផ្ទេរថ្នាំតាមបទបញ្ជាជូនដល់អស់លោកអ្នក ។ ជាឱសថស្ថានមួយអាចផ្ដល់ភាពជឿជាក់ដល់គ្រួសារអ្នក ។






យើងខ្ញុំនិយាយភាសាខ្មែរ ។

**លេខទូរស័ព្ទ 978-455-6554**

**លេខហ្វាក់ 978-455-9476**

## 937 Gorham St Lowell, MA, 01852

Continued from page 10

# CPP HONORS 'SECOND BIRTH'...

reposting a message from last year along with the same stereotypical cartoon of a Vietnamese man in a conical hat setting fire to a house in 1975 and returning to put out the fire in 1979.

"If the communist Vietnamese did not help the Khmer Rouge in the early 1970s there would be no 17 April 1975. Therefore, the major events that took place over the last 50 years were actively initiated and organised by the communist Vietnamese in order to control Cambodia and to mislead the Cambodian people," he wrote.

"Until now (2017) those who serve the interest of foreign aggressors continue to persecute Cambodian patriots-assassinating them or putting them in jail-in order to divide and weaken Cambodia so as to maintain our country under Vietnamese military and economic colonialism."

In a paper released on Friday titled "Moving Beyond the January 7 Narrative," the Future Forum think tank said the predictable debate over the meaning of January 7 was not only stale, but also preventing both parties from focusing on issues far more important to Cambodians today.

"Rather than establishing a viable policy platform, offering possible solutions to Cambodia's many problems, the two sides have stayed within their mythological comfort zones, asserting decades-old historical claims and counter-claims," the authors wrote.

"The guns may have fallen silent, but the old civil war rages on," it said, referring to battles throughout the 1980s between the Vietnamese-backed government in Phnom Penh and resistance forces on the Thai border, which Mr. Sokha and Mr. Rainsy were both part of.

Political analyst MeasNy said on Sunday that outside of old ruling party leaders and patrons, there was little interest in January 7 among an electorate that was anxious to hear how politicians could improve Cambodia's future.




"If the CPP continues to focus on this, they will lose supporters-young people have not interest," he said, noting that the CNRP, apart from Mr. Rainsy, had given the CPP a pass this year, likely hoping to continue sensitive talks to release prisoners caught up in seemingly political cases.

However, Mr. Ny said the timing of Mr. Sokha's trip to Takeo was no accident.

"They don't want to say anything, but they spend time to visit Kem Ley," he said. "It shows the public they care about Kem Ley and not January 7."

**(Additional reporting by Colin Meyn)**

---

តមកពីទំព័រទី ១២ បុរសម្នាក់នៅខេត្តព្រៃវែងស្រមៃចង់...

លោក សេក យាង មេឃុំព្រៃឈរគាំទ្រគម្រោងរបស់លោក ប៉ែន ឡុង ដោយលើកឡើងថា មានមនុស្សម្នាក់មកពីឃុំរបស់លោកព្យាយាមធ្វើអ្វីដែលថ្មី ហើយប្លែកសមនឹងទទួលបានការគាំទ្រ។ លោកបានមានប្រសាសន៍ថា "ខ្ញុំមិនដឹងថា តើយន្តហោះនេះអាចហោះបាន ឬមិនបាននោះទេ ប៉ុន្តែយើងត្រូវរង់ចាំមើលសិន"។

កាលពីប៉ុន្មានសប្តាហ៍កន្លងមកនេះ គម្រោងរបស់លោក ប៉ែន ឡុង ត្រូវបានផ្សព្វផ្សាយចែករំលែកពាសពេញបណ្តាញទំនាក់ទំនងសង្គម ហើយលោក ជា សុមេធី អភិបាលខេត្តព្រៃវែង ក៏បានចុះទៅជួបគាត់ដែរកាលពីរសៀលម្សិលមិញ។

ទោះជាយ៉ាងណាមានការផ្តែផ្តាំឱ្យប្រុងប្រយ័ត្នកាលពីម្សិលមិញពីលោក កែវ ស៊ីវន អ្នកនាំពាក្យអាកាសចរណ៍ស៊ីវិល។ លោកបានលើកឡើងថា ទោះបីវាជាគម្រោងដ៏អស្ចារ្យដែលគួរត្រូវបានលើកទឹកចិត្តក៏ដោយតែលោក ប៉ែន ឡុង គួរតែឱ្យអ្នកជំនាញបច្ចេកទេសពិនិត្យជាមុនសិនមុនពេលព្យាយាមហោះហើរជាលើកដំបូងដើម្បីសុវត្ថិភាពផ្ទាល់ខ្លួនរបស់លោក។ លោកបានបន្ថែមថា ហើយដោយសារតែក្នុងករណីនេះ លោក ប៉ែន ឡុង មិនគួរព្យាយាមហោះហើរជិតយន្តហោះផ្សេងៗទៀតនោះឡើយនៅថ្ងៃសាកល្បង៕ **ស៊ុយ ឈាង**







តមកពីទំព័រទី ១០

## CPP អបអរ "ថ្ងៃកំណើតទី២"...

មុខផ្ទួរលោក កែម ឡី អ្នកវិភាគនយោបាយ ដែលត្រូវខ្មាន់កាំភ្លើងបាញ់សម្លាប់ និងបានជួបជាមួយក្រុមគ្រួសាររបស់លោក ព្រមទាំងថតរូបបង្ហោះតាមហ្វេសប៊ុកទៀតផង។

លោក កឹម សុខា បានសរសេរសារបង្ហោះតាមហ្វេសប៊ុកថា "នេះជាលើកដំបូងដែលខ្ញុំបានមកគោរពវិញ្ញាណក្ខន្ធលោកបណ្ឌិត កែម ឡី ផ្ទាល់ នៅផ្ទះរបស់លោកក្នុងគេហដ្ឋានរបស់លោក" ហើយបានគូសបញ្ជាក់ថា គ្រាចុងក្រោយបង្អស់ដែលលោកទាំងពីរបានជួបគ្នាលោកទាំងពីរបានពិភាក្សាគ្នាផ្តោតជាសំខាន់លើយុទ្ធសាស្ត្របោះឆ្នោតឃុំសង្កាត់។

លោកបានសរសេរអំពីអ្នកវិភាគរូបនេះដែលត្រូវខ្មាន់កាំភ្លើងបាញ់ស្លាប់កាលពីខែកក្កដា ដែលមជ្ឈដ្ឋានជាច្រើនជឿថា ជារឿងនយោបាយថា "សូមវិញ្ញាណក្ខន្ធលោកបណ្ឌិត កែម ឡី បានទៅដល់ស្ថានសុគតិភព ហើយយើងខ្ញុំនឹងនៅតែបន្តស្វែងរកយុត្តិធមិជូនលោកបណ្ឌិត"។

លោក សម រង្ស៊ី ប្រធានគណបក្សប្រឆាំងដែលត្រូវបាននិរទេសជាផ្លូវការចេញពីប្រទេសកម្ពុជា បានចូលទៅកាន់បណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុកដែលលោកតែងតែធ្វើនៅថ្ងៃ៧មករា ដោយបានបង្ហោះឡើងវិញនូវសារកាលពីឆ្នាំមុនអមដោយរូបថ្លុកដដែលនៃបុរសវៀតណាមពាក់ដួនម្នាក់ដុតបំផ្លាញផ្ទះនៅឆ្នាំ១៩៧៥ ហើយត្រឡប់មកពន្លត់ភ្លើងវិញនៅឆ្នាំ១៩៧៩។

លោកបានសរសេរថា "បើគ្មានពួកយួនកុម្មុយនិស្តជួយខ្មែរក្រហមនៅដើមទសវត្សរ៍ឆ្នាំ ១៩៧០ ក៏គ្មានថ្ងៃ១៧មេសា ១៩៧៥ដែរ។ ដូច្នេះមួយផ្នែកធំនៃរឿងរ៉ាវទាំងអស់ក្នុងរយៈពេលជិត ៥០ឆ្នាំកន្លងមកនេះ គឺមានការរៀបចំយ៉ាងសកម្មដោយយួនកុម្មុយនិស្តដើម្បីលេបត្របាក់ទឹកដីយើង និងបំភាន់ភ្នែកប្រជារាស្ត្រខ្មែរ។ មកដល់ពេលនេះ (ឆ្នាំ២០១៧) ពួកអ្នកបម្រើផលប្រយោជន៍បរទេសឈ្លានពាននៅតែធ្វើបាប និងរករឿងខ្មែរគ្មានឥតឈប់ឈរ (រហូតដល់លួចសម្លាប់ ឬតាមចាប់ដាក់គុកអ្នកស្នេហាជាតិ)? ដើម្បីឱ្យប្រទេសជាតិយើងបែកបាក់ក្នុងគោលបំណងរក្សាអាណានិគមនិយមវៀតណាមមកលើប្រទេសកម្ពុជា"។

នៅក្នុងកំណត់ត្រាសិក្សាមួយចេញផ្សាយកាលពីថ្ងៃសុក្រដែលមានចំណងជើងថា "ការធ្វើដំណើរឱ្យហួសថ្ងៃ៧មករា" (Moving Beyond the January 7 Narrative) អង្គការវេទិកាអនាគតបានលើកឡើងថា ការជជែកដេញដោលអំពីអត្ថន័យ នៃថ្ងៃ៧មករា មិនត្រឹមតែជារឿងចាស់គំរិលនោះទេប៉ុន្តែថែមទាំងធ្វើឱ្យគណបក្សទាំងពីរមិនបានផ្តោតយកចិត្តទុកដាក់លើបញ្ហានានាដែលមានសារៈសំខាន់ជាងនេះឆ្ងាយចំពោះប្រជាពលរដ្ឋកម្ពុជានាពេលបច្ចុប្បន្នទៀតផង។

អ្នកសរសេរកំណត់សិក្សានេះបានលើកឡើងថា "ជំនួសឱ្យការបង្កើតកម្មវិធីនយោបាយដែលអាចសម្រេចបាន ដោយផ្តល់ដំណោះស្រាយអាចទៅរួចដើម្បីដោះស្រាយបញ្ហាជាច្រើនរបស់កម្ពុជា ភាគីទាំងពីរនៅតែស្ថិតក្នុងស្ថានភាពរបស់ខ្លួនដដែលពោលគឺពួកគេបន្តអះអាងប្រឆាំងគ្នាទៅវិញទៅមកជាច្រើនទសវត្សរ៍ពាក់ព័ន្ធប្រវត្តិសាស្ត្រ"។

សំដៅដល់សមរភូមិច្បាំងគ្នាពេញ១ទសវត្សរ៍ឆ្នាំ១៩៨០ រវាងរដ្ឋាភិបាលដែលគាំទ្រដោយវៀតណាមនៅភ្នំពេញ និងកងកម្លាំងតស៊ូនៅព្រំដែនថៃ ដែលលោក កឹម សុខា និងលោក សម រង្ស៊ី សុទ្ធតែមានចំណែកពាក់ព័ន្ធនោះ កំណត់ត្រានេះបានបន្តថា "កាំភ្លើងបានស្ងប់ស្ងាត់ហើយ ប៉ុន្តែសង្គ្រាមស៊ីវិលចាស់នៅតែបន្ត"។

លោក មាស នី អ្នកវិភាគនយោបាយបានមានប្រសាសន៍កាលពីម្សិលមិញថា ក្រៅពីថ្នាក់ដឹកនាំរបស់គណបក្សកាន់អំណាច និងអ្នកគាំទ្ររបស់ខ្លួនមានការចាប់អារម្មណ៍តិចតួចណាស់លើថ្ងៃ៧មករា ក្នុងចំណោមអ្នកបោះឆ្នោតដែលអន្ទះសាចង់ដឹងពីវិធីដែលអ្នកនយោបាយអាចធ្វើឱ្យអនាគតរបស់កម្ពុជាប្រសើរឡើង។

លោកបានថ្លែងថា "បើគណបក្សប្រជាជនកម្ពុជាបន្តផ្តោតលើរឿងនេះ ពួកគេនឹងបាត់បង់អ្នកគាំទ្រ យុវជនមិនចាប់អារម្មណ៍ទេ"។

ហើយលោកបានគូសបញ្ជាក់ថា គណបក្សសង្គ្រោះជាតិក្រៅពីលោកសមរង្ស៊ីមិនចាប់អារម្មណ៍រឿងគណបក្សប្រជាជនកម្ពុជាឡើយនៅឆ្នាំនេះ ដោយទំនងជាសង្ឃឹមបន្តការជជែកដ៏រសើបដើម្បីឱ្យមានការដោះលែងអ្នកទោសដែលត្រូវបានចាប់ខ្លួនក្នុងសំណុំរឿងនយោបាយ។

ទោះជាយ៉ាងណា លោកបានលើកឡើងថា ពេលវេលានៃការធ្វើដំណើររបស់លោក កឹម សុខា ទៅកាន់ខេត្តតាកែវមិនមែនជារឿងចៃដន្យឡើយ។ លោកមានប្រសាសន៍ថា "ពួកគាត់មិនចង់និយាយអ្វីទាំងអស់ ប៉ុន្តែពួកគាត់ចង់ចំណាយពេលទៅជួបលោក កែម ឡី។ វាបង្ហាញដល់សាធារណជនថា ពួកគាត់យកចិត្តទុកដាក់ចំពោះលោក កែម ឡី មិនមែនថ្ងៃ៧មករានោះទេ"៕

សុខុម (រាយការណ៍បន្ថែមដោយ Colin Meyn)




## តមកពីទំព័រទី ១៩ ទស្សនាព្រះសក្យមុនីចេតិយនៅលើ...

ប្រជាជនខ្មែរជាអ្នកកាន់ពុទ្ធសាសនាមិនអាចគាស់រំលាយព្រះពុទ្ធប្បដិមានោះឡើយ ។ ដូចនេះទើបស្ដេចចិនបញ្ជាឱ្យគេសាងសង់ព្រះពុទ្ធប្បដិមាកំពស់១៨ហត្ថជាមុនសិនរួចទើបសង់ព្រះវិហារជាក្រោយដោយបែរមុខព្រះពុទ្ធប្បដិមាទៅទិសខាងជើងតំរង់ទៅស្រុកចិន ។ ចាកចេញពីព្រះវិហារនៃវត្តធម្មិកើ្តបន្តទៀត គឺជាកន្លែងសក្ការៈនានាសំរាប់បូជាទានធូបផ្កាភ្ញីមានដូចជាទីសក្ការៈរបស់ព្រះអង្គប្រោសសត្វ ព្រះអង្គខ្មៅ ព្រះគោព្រះកែវ ព្រះអង្គប្រក់នាគ និងលោកតាដំបងដែកដែលល្បីថា ពូកែសក្ដិសិទ្ធណាស់ ។ ព្រះសក្យមុនីចេតិយបានសាងសង់ឡើងយ៉ាងប្រណិតស្ថិតនៅលើកំពូលភ្នំខ្ពស់ជាងគេនៅផ្នែកខាងជើងមានកំពស់៤០ម៉ែត្របានបញ្ចុះបឋមសិលានៅថៃ្ងទី៨ ខែសីហា ឆ្នាំ១៩៩៦ ជាទីកន្លែងតំកល់ព្រះសារីរិកធាតុរបស់ព្រះសម្មាសម្ពុទ្ធ ។ មនុស្សគ្រប់រូបដែលមកដល់បិរវេណនេះតំរូវឱ្យដោះស្បែកជើង និងដោះមួកចេញដោយដើរទស្សនាជើងទទេរ ហើយផ្នែកខាងក្រោមព្រះសក្យមុនីចេតិយពុទ្ធបរិស័ទគ្រប់ទិសទីបាននាំគ្នាជាវព្រះពុទ្ធរូបមកតំកល់ទុកទីនេះចំនួន៥៣៣៤ អង្គនេះបើតាមស្ថិតិរបស់ក្រសួងវប្បធម៌ ។ នៅទីកន្លែងផ្សេងមិនធ្លាប់មានតម្កល់ព្រះពុទ្ធប្បដិមាយ៉ាងច្រើនបែបនេះឡើយ ព្រះពុទ្ធប្បដិមានិមួយៗបានរៀបចំឡើងយ៉ាងមានសណ្ដាប់ធ្នាប់ក្រោមពន្លឺភ្លើងភ្លឺចែងចាំងដ៏ស្រស់ស្អាត គួរជាទីជ្រះថ្លាក្រៃលែង ។ ភ្ញៀវជាតិ និងអន្តរជាតិដែលបានមកទស្សនានៅទីនេះ មានសេចក្ដីសោមនស្សរីករាយទាំងគ្រហស្ថរួមទាំងព្រះសង្ឃបានមកគោរពថ្វាយទានធូប ផ្កាភ្ញីបូជាថ្វាយព្រះជាហូរហែរ ជាពិសេសនៅថៃ្ងសំរាក ។ ជារៀងរាល់ឆ្នាំពុទ្ធបរិស័ទឆាយជិតបានប្រារព្ធពិធីបុណ្យសំខាន់ៗក្នុងព្រះពុទ្ធសាសនា ដូចជាបុណ្យពិសាខបូជាបុណ្យមាឃបូជា និងពិធីដង្ហែរអង្គកឋិនទានមកកាន់វត្តនេះសូត្រធម៌មនស្កាព្រះរតនត្រ័យព្រមទាំងសម្ដែងធម៌ទេសនាដោយលោកគ្រូអគ្គបណ្ឌិតបុតសាវង្សនៅលើកំពូលភ្នំព្រះរាជទ្រព្យនៃបរិវេណព្រះសក្យមុនីចេតិយនេះ ។ នៅខាងឆ្វេងដៃក្បែរព្រះសក្យមុនីចេតិយមានចេតិយធំៗចំនួនពីរនៅក្បែរគ្នាចេតិយខាងជើងមានឆ្លាក់រូបដំរីដែលគេហៅថា "ចេតិយសាមពាន់"កសាងឡើងក្នុងគ្រិស្តសករាជ១៦២៣ ដោយព្រះបាទជ័យជេដ្ឋា ដើម្បីបញ្ចុះព្រះបរមអដ្ឋិនៃព្រះបាទស្រីសុរិយោពណ៌ជាព្រះរាជបិតាចេតិយខាងត្បូងជាប់គ្នានោះកសាងឡើងក្នុងគ្រិស្តសករាជ ១៨៩១ដោយព្រះបាទសម្ដេចព្រះនរោត្តម ដើម្បីបញ្ចុះព្រះបរមអដ្ឋិនៃព្រះបាទ អង្គឌួង ជាព្រះរាជបិតា បើឡើងតាមជណ្ដើខាងត្បូងឃើញមានចេតិយធំមួយ គឺជាចេតិយរបស់សម្ដេចព្រះបាទស៊ីសុវត្ថិ មុនីវង្ស ដែលមានក្បាច់រចនាស្អាតបាតចំណែកឯចេតិយធំទាំងបីដែលស្ថិតនៅលើភ្នំជ្រុងខាងជើងត្រូវបាន ហៅថា "ចេតិយត្រៃត្រិង្ស" ។

ចុះពីលើភ្នំទៅខាងក្រោមមានទីធ្លាធំទូលាយមានលក់ម្ហូបអាហារច្រើនស្អេកស្កះនិងវត្តអនុស្សាវរីយ៍មួយចំនួននិងមានតូបជាច្រើនសំរាប់អង្គុយលេងកំសាន្តនិងញ៉ាំអាហារជាលក្ខណៈគ្រួសារ និងស្រូបយកខ្យល់អាកាសបរិសុទ្ធយ៉ាងសប្បាយរីករាយ ។ **ពិន នារីពិទូ**


# HIRING EVENT!
# ពិធិជ្រើសរើសបុគ្គលិក

**Our clients are looking for warehouse, general labor, manufacturing and production workers for immediate openings!!**

ក្រុមហ៊ុនជាដៃគូរបស់យើងកំពុងត្រូវការបុគ្គលិកធ្វើការនៅតាមឃ្លាំង, ពលករប្រើកកម្លាំងសុទ្ធ, បុគ្គលិកធ្វើការតាមរោងចក្រឧស្សាហកម្ម និង រោងចក្រផលិតកម្មនានា សម្រាប់បំពេញសេចក្ដីត្រូវការភ្លាមៗ !

**When: Wednesday January 25, 2017 from 10AM - 2PM.**

**ពេលណា ៖** ថ្ងៃពុធ ទី ២៥ មករា ២០១៧ ពីម៉ោង ១០ ព្រឹកដល់ម៉ោង ២ រសៀល

**Where: Cambodian Mutual Assistance Association**
**465 School St Lowell, MA 01851**

ទីណា ៖ ការិយាល័យសមាគមខ្មែរ (CMAA)

**What to bring: Two forms of IDs and a resume**

**ត្រូវយកអ្វីមកជាមួយ ៖** អត្តសញ្ញាណប័ណ្ណ ២ សន្លឹក និង ឯកសារប្រវត្តិការងារ

**Interested in speaking to a recruiter?**
**Schedule your interview today!**

**តើអ្នកចាប់អារម្មណ៍ចង់ពិភាក្សាជាមួយអ្នកជ្រើសរើសបុគ្គលិកមែនទេ?**
**សូមដាក់ម៉ោងណាត់ជួបដើម្បីសុំធ្វើសម្ភាសន៍នៅថ្ងៃនេះតែម្ដង !**

**Please call or email us to schedule an interview time.**

សូមទូរស័ព្ទ ឬផ្ញើអ៊ីម៉េលមកយើងខ្ញុំដើម្បីដាក់ម៉ោងណាត់ជួបសម្ភាស ។

Express Employment Professionals
Tel: (978)-258-0609
Andoverma@expresspros.com





# CONWAY
INSURANCE AGENCY

**រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវេយបានបម្រើសហគមន៏ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងលែន ។**

**យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :**

**ការធានារ៉ាប់រងគ្រួសារ**
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បះ
- វត្ថុបុរាណ

**ការធានារ៉ាប់រងជំនួញ**
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- វិកខឺខម (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការ៉ាស់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង



# Red Rose
ភោជនីយដ្ឋាន កូលាបក្រហម RESTAURANT
ម្ចាស់ថ្មី -ម្ហូបឈ្ងុយឆ្ងាញ់

Pailin Plaza
716 Middlesex St. Ste 1
Lowell, MA 01851

អញ្ជើញមកចូលរួមមិនខុសបំណងទេ សូមអរគុណ!

Mon-Sun
8am -8pm




បាយសាច់ជ្រូកពងទាចៀន



គុយទាវអូរឬស្សី



មីកន្ដាំង



បបរគ្រឿង


*ម្ហូបឆ្ងាញ់ជាងមុន តែតម្លៃនៅថោក ដូចមុនដដែល
*សេវាកម្មរហ័សទាន់ចិត្ត និងរួសរាយរាក់ទាក់

(978) 452-5400




# NOTICE OF PUBLIC MEETING

The Northern Middlesex Metropolitan Planning Organization (NMMPO) will meet at 2:30 P.M. on January 26th, 2017 at the Northern Middlesex Council of Governments office, 40 Church Street, Suite 200, Lowell, MA. The NMMPO will discuss FFY 2017-2021 Transportation Improvement Program (TIP) adjustments.In addition, the NMMPO will vote to release a draft TIP amendment and an amendment to the Public Participation Plan for a 30-day public comment period. The full agenda can be found at www.nmcog.org. Please note that the TIP contains the program of projects for the Lowell Regional Transit Authority (LRTA). The MPO's public participation process satisfies the LRTA's public participation requirements for the program of projects.

Notice: This location is accessible to people with disabilities and is near public transportation. NMCOG offers secure bicycle parking on the second floor. The NMMPO provides reasonable accommodations and/or language assistance, free of charge, upon request (including, but not limited to, interpreters in American Sign Language and languages other than English, open or closed captioning for videos, assistive listening devices and alternate material formats), as available. For assistance, please contact Justin Howard at (978) 454-8021, ext 121 or at jhoward@nmcog.org . Requests should be made as soon as possible for services requiring advanced arrangements, including sign-language, CART or language translation or interpretation.

# សេចក្តីជូនដំណឹង ការរៀបចំកិច្ចប្រជុំជាសាធារណៈ

ការិយាល័យផែនការក្រុងនូសធនម៉ិដូលសិច (NMMPO) នឹងមានការរៀបចំកិច្ចប្រជុំមួយនៅទីស្នាក់ការក្រុមប្រឹក្សារដ្ឋបាលនូសធនម៉ិដូលសិចនៅម៉ោង ២:៣០ នាទីរសៀលដែលមានទីតាំងស្ថិតនៅផ្លូវ៤០ Church Street, Suite 200, Lowell, MA។ ក្នុងជំនួបនេះ ការិយាល័យ NMMPO នឹងធ្វើការពិភាក្សាលើប្រធានបទស្តីពីការធ្វើកំណែទំរង់លើគម្រោងកម្មវិធីធ្វើឱ្យប្រសើរឡើងនូវគមនាគមន៍ (TIP) ឆ្នាំ២០១៧-២០២១។ ជាងនេះទៅទៀត NMMPO ក៏នឹងធ្វើការបោះឆ្នោតផងដែរ ដើម្បីដាក់ចេញការធ្វើវិសោធនកម្មលើសេចក្តីពង្រៀងនៃគម្រោង TIP និងការផ្លាស់ប្តូរចំពោះគម្រោងនៃការចូលរួមសម្តែងមតិជាសាធារណៈសម្រាប់រយៈពេល៣០ថ្ងៃវិញ។ លោកអ្នកអាចទទួលបានព័ត៌មានពីរបៀបវិរៈនៃកិច្ចប្រជុំដោយគ្រាន់តែចូលទៅកាន់វេបសាយ www.nmcog.org នេះ។ សូមរំលឹកថា ក្នុងគម្រោង TIP នេះ ក៏មានរួមបញ្ចូលទាំងកម្មវិធីនៃគម្រោងជាច្រើនសម្រាប់អាជ្ញាធរគមនាគមន៍ថ្នាក់តំបន់ឡូវែល (LRTA)ផងដែរ។ ដំណើរការនៃការរៀបចំប្រជុំចូលរួមជាសាធាណៈរបស់ការិយាល័យផែនការក្រុងនេះ គឺវាសមស្របទៅនឹងតំរូវការឱ្យមានការចូលរួមជាសាធាណៈរបស់អាជ្ញាធរ LRTA សម្រាប់កម្មវិធីនៃគម្រោងជាច្រើនរបស់ខ្លួន។

**កំណត់ចំណាំ:**

ទីតាំងនៃការរៀបចំកិច្ចប្រជុំនេះងាយស្រួលសម្រាប់ឱ្យជនពិការចេញចូល និងនៅជិតនិងចំណតឡានក្រុង។ ការិយាល័យ NMMPO មានទីតាំងសុវត្ថភាពសម្រាប់ចំណតកង់ដែលស្ថិតនៅជាន់ទី២ ។ សម្រាប់ជំនួបនេះ NMMPO ក៏ផ្តល់ផងដែរនូវការស្នាក់នៅ និង,រឺ ជំនួយផ្នែកភាសាដោយមិនគិតថ្លៃ (មានដូចជាអ្នកបកប្រែជាភាសាអង្លេស និងភាសាផ្សេងទៀត, បកប្រែភាសាតាមរយៈការថតរូបឬឧបករណ៍បកប្រែជាសម្លេងសម្រាប់អ្នកគរ ថ្លង់ និងជនពិការភ្នែកព្រមទាំងការចែកជូនឯកសារផ្សេងទៀត) ប្រសិនបើមានការស្នើរសុំ។

សម្រាប់ការចូលរួមរបស់លោកអ្នក និងព័ត៌មានបន្ថែមពីការប្រជុំនេះសូមទំនាក់ទំនងលោក Justin Howard តាមរយៈលេខទូរសព្ទ (៩៧៨) ៤៥៤-៨០២១, ខេត ១២១ រឺអ៊ីមេលទៅកាន់jhoward@nmcog.org ។ រាល់ការស្នើរសុំជំនួយនានា ដូចជាភាសាកាយវិកា, ការបកប្រែផ្ទាល់ៗ រឺការបកប្រែភាសា សូមទំនាក់ទំនងមកយើងខ្ញុំជាមុន ដើម្បីងាយស្រួលក្នុងការរៀបចំ ៕

## បើកទំព័រថ្មីសម្រាប់ទទួលយោបល់លោកអ្នកអាន

ដើម្បីចូលរួមស្វាគមន៏ឆ្នាំ២០១៧, យើងមានសេចក្តីរីករាយនឹងបើកទំព័រថ្មីម្រាប់ទទួលផ្សាយដោយសេរីនូវគំនិតយោបល់នឹងព័ត៌មានផ្សេងៗដែលលោកអ្នកអានមានបំណងធ្វើការផ្សព្វផ្សាយជាសាធារណៈនៅរៀងរាល់ពេលដែលយើងទទួលបាននូវអត្ថបទថ្មីពីលោកអ្នក។

សូមផ្ញើរអត្ថបទ រូបថត ឬ រូបគំនូរ មក info@khmerpost.us សម្រាប់អ្នកដែលចេះប្រើ "អាំងទែណេត" ឬក៏ផ្ញើរមកអស័យដ្ឋាន Khmerpost U.S.A. Editorial

45, Merrimack Street, #218A

Lowell, Lowell MA 01852_USA

សូមសរសេរដោយដៃក្នុងចន្លោះខាងក្រោមនេះរួចកាត់ផ្ញើរមកយើងខ្ញុំ

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

យើងជឿជាក់ថា គំនិត យោបល់ នឹងព័ត៌មានពីលោកអ្នកនឹងជួយជាប្រយោជន៏ដល់សហគមន៏ញាតិមិត្ត ក្រុមគ្រួសារជាមិនខាន។ សូមកុំភ្លេចដាក់ឈ្មោះ ឬដាក់រូបថត សម្រាប់សំគាល់ម្ចាស់អត្ថបទផង។ **-សូមអរគុណ-**

**KhmerPost USA, LLC**

**សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក**

អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852

លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092

អ៊ីម៉ែល info@khmerpost.us

អានកាសែតនៅគេហទំព័រ www.khmerpost.us

**ផ្សាយពាណិជ្ជកម្ម Advertising**

អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*

លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)

អ៊ីម៉ែលsobenpin@khmerpost.us

**អ្នកនិពន្ធ Editorials**

និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*

(978) 942 - 1641 | rogerpin@khmerpost.us

កាវីនិពន្ធ Staff Writers:

អ្នកនិពន្ធកិត្តិយស **Contributing Writers:**

Richard Howe Jr,

**ច្នៃសោភ័ណភាពកាសែត Design Artist**

Heng Chhunleng

**ជំនួយការរដ្ឋបាល** Office Coordnator

Sochet Chhen

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009

Follow us: Facebook | Twitter @KhmerpostUSA

( អស័យដ្ឋានអ្នកផ្ញើរ )

បិតតែម

Khmerpost U.S.A., Editorial Dep.
45, Merrimack Street, #218A
Lowell, Lowell MA 01852_
USA

បត់ជា២...........................................................................................

**អត្ថបទក្នុងសំបុត្រនេះ:**
**១-** ជាអត្ថបទ ឬ ព័ត៌មាន សុំឱ្យចុះផ្សាយ
**២-** ជាសំនួរ សុំឱ្យឆ្លើយតាមទំព័រកាសែត
**៣-** ជាសំនួរ សុំឱ្យឆ្លើយតប មិនឱ្យផ្សាយទេ
សំបុត្រនេះអាចបត់ជាពីរ បិទការខាង២ បិតតែមមួយ រួចផ្ញើរមកយើងតាមប៉ុស្តិ៍
- សូមគូសនៅ ១-២ ឬ ៣ ដែលត្រូវនឹងសំបុត្រនេះ


# MARCOTTE LAW FIRM
## ក្រុមហ៊ុនមេធាវី Marcotte

45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

- សេចក្តីអន្តរាយដល់បុគ្គល
- សំណងបុគ្គល
- ពិការភាពដោយសន្តិសុខសង្គម
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
- បណ្តឹងវិវាទទូទៅ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍
- ច្បាប់ធានារ៉ាប់រង
- ការរំលោភបទព្រហ្មទណ្ឌ
- គ្រោះថ្នាក់ចរាចរណ៍
- គ្រោះថ្នាក់នៅការដ្ឋាន
- បំណុលអចលទ្រព្យ

**មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទ**
**មកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ**

**(978) 458-1229**

**www.marcottelawfirm.com**



Element Care

# ខ្ញុំគ្មានការព្រួយបារម្ភទៀតទេ។



ការផ្តល់សេវាធ្មេញដោយឥតគិតថ្លៃ

ការផ្តល់ជូននូវយានជំនៈដោយឥតគិតថ្លៃ

ផ្តល់ជូនវ៉ែនតានិងឧបករណ៍
ជំនួយការស្តាប់ដោយឥតគិតថ្លៃ

ការថែទាំតាមផ្ទះនិងផ្តល់ជូននូវ
អាហារដោយឥតគិតថ្លៃ

ផ្តល់ជូននូវថ្នាំតាមវេជ្ជបញ្ជាដោយឥតគិតថ្លៃ

## នៅជាមួយនឹងកម្មវិធី PACE នៃអង្គការ Element Care, ការថែរក្សានឹងការចំណាយរបស់ខ្ញុំគឺត្រូវបានទទួលខុសត្រូវទាំងស្រុងជំនួសខ្ញុំ។

អ្នកដែលមានសិទ្ធិមាន MassHealth នឹង Medicare គឺមិនត្រូវបង់ថ្លៃទេ។ សូមទាក់ទងមកយើងខ្ញុំបើអ្នកមានតែ Medicare ហើយនឹងការបង់ថ្លៃដោយឯកជន។ គ្រប់សមាជិកទទួលបាននូវការថែទាំសុខភាព, សេវាកម្មពេទ្យឯកទេស-លើកលែងតែសេវាកម្មសង្គ្រោះបន្ទាន់-ដូចជាបានអនុញ្ញាតពីកម្មវិធី PACE, ពុំនោះទេនឹងទទួលខុសត្រូវដោយខ្លួនឯងចំពោះថ្លៃសេវាកម្មមិនបានអនុញ្ញាតជាមុន។
H2222_2016_3K

សូមអញ្ជើញ
ទាក់ទងមកកាន់ទូរសព្ទលេខខាងក្រោមនេះ

1-877-803-5564
(TTY 711)
ឬក៏តាមរយ:
elementcare.org




**តពីលេខមុន**

ព្រឹកនេះយើងទៅហាងខាងត្បូងផ្សារ ចិនឡូឡាបន្តិច តែធ្វើគុយទាវលឿនហើយឆ្ងាញ់ផង។ ទៅផ្សារជុំគ្នារបៀបនេះជាឱកាសរីករាយដ៏រវល់នឹងដ៏កម្រដែលចៅពិនមានភារៈកិច្ចធំជាងគេត្រូវមើលអាក្មួយតូចៗកុំឱ្យដើរបាត់ក្នុងចំណោមមនុស្សប្រច្រៀតគ្នាយ៉ាងណែនទិញត្រីស្រស់ៗលោតពេញកម្រាលថ្មតដ្ឋ "ការ៉ូ" សង់ឡើងសម្រាប់ពួកអ្នកលក់ត្រីនៅទាបនឹងដី -រីឯអ្នកលក់សាច់ជ្រូក ឬសាច់គោគេលក់នៅក្នុងទ្រុងសំណាញ់កុំឱ្យរុយរោមក្នុងផ្សារផ្នែកខាងក្រោយ, អ្នកទិញចង្អុលសាច់ដែលចង់បានពីតាមប្រឡោះដូចទៅទិញសំបុត្រចូលទៅមើលកុនដែរ -ឬសាច់មាន់សាច់ទាគេដាក់ខ្ពស់ទាំងរស់ ឬលក់សាច់លើតុដែលគេយកមកខ្លួនឯង។ ដើរទៅដល់តូបគ្រឿងទេស ដើម្បីទិញខ្ទឹម ម្រេច ស្ក អំបិល ឬក៏ខាងបន្លែបង្ការ សណ្ដែក ត្រពាំង ស្លឹកគ្រៃ តំឡូង...។ល។ ឬក៏មាន់ ទា រស់ កន្លែងទាំងនោះមិនចង្អៀតពេកទេ។ បងសូនីទិញម្ហូបអាហារបានច្រើនដាក់កន្ត្រកមួយពេញធ្ងន់ពេកគាត់ឱ្យចៅពិន ជួយយួរ នៅពេលត្រឡប់មកផ្ទះវិញ រីឯខ្លួនគាត់កាន់កញ្ចប់ផ្សេង២-៣ទៀត នឹងដឹកដៃ "អាព្រឿង" ចំណែកចៅពិនដើរផង មើល "អាធា" ជាក្មួយផងកុំឱ្យបាត់, នាំគ្នាដើរមកផ្ទះវិញយ៉ាងរីករាយកាត់តាមមុខហាងដែលបងសូនីធ្លាប់ស្គាល់និយាយប្តូរយោបល់គួរសមដាក់គ្នា នាពេលព្រឹកនាំអារម្មណ៍ល្អៗត្រឡប់ជាមួយម្ហូបអាហារមកផ្ទះវិញផង។ បងសូនីបានប្អូនមកលេងគាត់ធ្វើម្ហូបឆ្ងាញ់ៗជាពិសេសឱ្យគ្រួសារញ៉ាំបានឆ្ងាញ់មាត់ស្មើរាល់ពេល។

ល្ងាចនេះដល់ពេលឪពុកចៅពិនត្រូវមកទទួលកូនទៅផ្ទះវិញ នៅឯបន្ទាយនៅភូមិ "រោងគោ" ដែលស្ថិតនៅប្រមាណកន្លះម៉ោងដោយថ្មើជើងទៅខាងត្បូងទីប្រជុំជន បន្ទាប់ពីបរិវេណសាលាខេត្តទៅ។ ចៅពិនដឹងថា នៅពេលត្រឡប់ទៅបន្ទាយវិញ នឹងមិនបានលេងសប្បាយដូចនៅផ្ទះផ្សារជាមួយបងសូនីទេ ម្ល៉ោះហើយចិត្តមិនទាន់ចង់ទៅវិញទេ, តែគេផ្តើមនឹកទៅដល់កង់ដែលធ្លាប់វាយរត់លេងនឹងមិនអាចយកទៅបានទេ នឹកទៅដល់គូរកនជាមិត្ត "គប់វង់" ឬមិត្តលេង "អាគិញអាចោរ" ឬក៏ "ស្រណោះលេងទឹកស៊ីង" ទៅហើយ... ធ្វើឱ្យគេភ្លេចខ្លួនស្រងូតក្នុងចិត្តនាំឱ្យបងស្រីចាប់អារម្មណ៍ក៏សួរថា:

-អូនពិន ឯងកើតអីហើយបានជាមិនសូវនិយាយស្តីអីដូចមុនៗ?

-ខ្ញុំអត់អីទេអ្នកបង, ហើយក៏ស្ងៀមស្ងាត់បន្តទៅទៀតយ៉ាងចម្លែក...

ចៅពិនដើរចេញទៅក្រៅក្រែងបានជួបក្មេងឯទៀតគ្រាន់និយាយលេងបានជួប "អាប្លួច" កូនស្រី




អ្នកជិតខាងជាប់ផ្ទះគ្នា ក៏ទៅលេងនឹងគេនៅផ្ទះបាយមើលម្ដាយអាផ្លួចចិតបន្លែដាក់ដបធ្វើជ្រក់ទុកម្ដាយអាផ្លួចក៏សួរថា:

-ក្មួយឯងរៀបខ្លួនទៅណាក៏ស្អាតបាតម្ល៉េះថ្ងៃនេះ? មែន! ចៅពិន រសៀលនេះ ស្លៀកខោខ្លីថ្មី អាវដៃខ្លីថ្មី ពាក់ស្បែកជើងផ្ទាត់កៅស៊ូ ខុសពីធម្មតាដែលតែងទុកដងខ្លួនទទេ, ពីព្រោះត្រូវត្រៀមខ្លួនឱ្យហើយ... ហើយក៏តបថា:

-ប៉ាខ្ញុំមកយកខ្ញុំទៅបន្ទាយនៅពេលបន្តិចទៀតនេះហើយ អ្នកមីង! ម្ដាយអាប្លួចជាភរិយាលោកបាឡាត់ស្រុកធ្វើការនៅជាប់សាលាខេត្ត គាត់ជួលផ្ទះនៅជាប់គ្នារាប់អានគ្រួសារបងស្រីចៅពិនបានល្អណាស់, គាត់សួរបន្តរថា:

-ក្មួយឯងទៅហើយ ពេលណាបានមកម្តងទៀត?

-ខ្ញុំឥតដឹងទេ ស្រេចតែនឹងប៉ាឱ្យមកបានខ្ញុំមកបាន!

-ចុះទៅបាត់ទៅបាននរណាលេងជាមួយអាប្លួចទៀត? ចៅពិន រាងឆ្ងល់ដែរ តាមធម្មតាអ្នកមីងនោះតែងតែឃាត់កុំឱ្យលេងច្រើនរំខានគាត់

-អាប្លួចលេងជាមួយអាប្អូនប្រុសបានទេតើ? ខ្ញុំតែទៅវិញគ្មានគ្នាលេងទេ បងៗខ្ញុំគេធំៗមិនលេងជាមួយខ្ញុំទេ! ជួនគ្នានឹងបងស្រីចៅពិនស្រែកហៅរកថា "ប៉ាមកដល់ហើយ!" ក៏ដាច់ការជជែកគ្នា ហើយជម្រាបលាអ្នកមីងនឹងអាប្លួចតែម្តង...

**១២-នៅបន្ទាយទាហ៊ាន "ជើងខ្មៅ"**

ឪពុកចៅពិនជិះឡាន "ហ្ស៊ីប" ទាហ៊ាន មានអ្នកបើកជាអ្នកជូនមក មកដល់ជួបនិយាយលេងនឹងកូនស្រីគាត់បន្តិចនិយាយលេងនឹងអាចៅស្រីបន្តិចៗម្នាក់យ៉ាងរីករាយរង់ចាំចៅពិនយកឥវ៉ាន់កំប៉ុកកំប៉ុកដាក់កាតាបរួចយកទៅដាក់ពីក្រោយឡាន រួចឡើងអង្គុយចាំឪពុករបស់ខ្លួននៅកៅអីខាងក្រោយឡាន "ហ្ស៊ីប" ជាស្រេច ។ និយាយគ្នាចប់ហើយក៏លាកូនស្រីចេញទៅ ចៅពិនសំពះលាបងស្រីពីក្នុងឡានបើកដំបូលសម្លឹងមើលទៅក្មួយមើលទៅ "អាប្លួច" ដែលតាមមើលពីក្រោយផ្ទះ មើលទៅអា "ពីម៉ុន" នឹង "អាពីសែន" ដែលតាមមើលគ្នាពីលើឡៅយ៉ាងអាឡោះអាល័យ នឹកថា មិនងាយនឹងបានជួបគ្នាទៀតទេ។ អ្នកបើកឡានហៅថា "សូហ្វ័រ" ឡានបើកចេញមកកាត់តាមស្ពានដែក តម្រង់ទៅតាមខាងត្បូងសាលាខេត្តសំដៅទៅបន្ទាយដែលនៅពីក្រោយនោះ ទៅដល់មុខបន្ទាយអ្នកយាមលើកអាវុធវន្ទាចំពោះចៅហ្វាយ ហើយទៅដោះច្រវ៉ាក់ឱ្យបើកឡានចូលទៅក្នុងបន្ទាយបាន រួចឡានហ្ស៊ីបបើកទៅដល់ផ្ទះកុម៉ង់ដង់ដែលជាផ្ទះធំធ្វើពីឈើខ្ពស់ពីដី ទើបឈប់ដាក់អ្នកជិះចេញពីឡាន។ លោកម៉ាំង ជាកុម្ម៉ង់ដង់ បន្ទាយជើងខ្មៅ ឪពុកចៅពិន ជាមេបញ្ជាការខ្មែរនៅបន្ទាយនោះមានឋានន្តរសក្តិជាអនុសេនីយឯក ។

ដែលគេហៅថាបន្ទាយជើងខ្មៅនោះ ពីព្រោះតែផ្នែកមួយនៃឯកសណ្ឋាន គឺ "សំបកត្រពាំង" ពាក់នឹងជើងសម្រាប់សំគាល់កងឯកភាព, កងឯកភាពណាដែលបញ្ជាដោយមេបញ្ជាការខ្មែរ គឺសម្គាល់ដោយសំបកត្រពាំងពណិខ្មៅ, កាលណាឃើញទាហ៊ានពាក់សំបកត្រពាំងពណិក្រហមគឺជាទាហ៊ានដែលមានមេបញ្ជាការបារាំង។ ពណិខុសគ្នានៃសំបកត្រពាំងនេះ បណ្ដាលឱ្យមានទំនាស់ជាញឹកញាប់ដែរ ដូចជានៅពេលបានច្បាប់ចេញទៅដើរលេងកំសាន្តក្នុងក្រុងនាល្ងាចថ្ងៃសៅរ៍ ទៅចូលហាងបាយទាំងក្រុម ឬទៅមើលល្ខោនបាសាក់ទៅចែចង់ស្រ្តីតែមួយនាំឱ្យវាយតប់គ្នា ហើយតម្រួតយោធា "ប៉េអឹម" តែងតែចាប់ដាក់គុកជាហូរហែរ, ប៉ុន្តែមិនដែលឮទំនាស់ដល់បាញ់គ្នាទេ ។

ទាហ៊ានខ្មែរតែងចេះនិយាយបារាំង បើមិនបានច្រើនក៏បានខ្លះដែរ, លោកមេបញ្ជាការ ម៉ាំង ចេះបារាំងច្បាស់លាស់ទាំងនិយាយនឹងសរសេរផង, ពីព្រោះនៅសាលារៀនខ្មែរមានកម្មវិធីរៀនខ្មែរតែ២-៣ឆ្នាំដំបូងទេ ត្រឹមនេះសាលារៀនមានទូទាំងប្រទេស ជាពិសេសនៅសាលាវត្តបន្តពីនោះទៅកម្មវិធិរៀនបារាំងស្ទើរគ្រប់វិញ្ញាសារទាំងអស់ ហើយត្រូវមករៀននៅទីក្រុងធំៗ, ម្ល៉ោះហើយតែសិស្សណារៀនបានដល់បញ្ចប់ថ្នាក់បឋមសិក្សា ហើយជាប់សញ្ញាប័ត្រ គឺជាសិស្សឆ្នើមទាំងភាសាបារាំង ទាំងគណិតសាស្ត្រ។ លោកម៉ាំង បានចូលសាលានាយទាហ៊ានបាន ក៏ដោយសារបានសញ្ញាប័ត្របឋមសិក្សារនោះ ចេញមកវិញគេឱ្យពាក់សក្តិ "អាស្ពិរ៉ង់" កាលពី១០ឆ្នាំមុន ហើយត្រូវគេបញ្ជូនទៅធ្វើការនៅស្ទឹងត្រែង ដែលនៅទីនោះហើយដែលលោកម៉ាំងបានជួបនឹងម្ដាយចៅពិន រៀបការគ្នាជាគូរស្វាមីភរិយា.. នៅទីនោះបាន២ឆ្នាំក៏ផ្លាស់មកភ្នំពេញតែម្តង ។ ម្ដាយចៅពិនជាស្ត្រីស្រុកចំការ មិនបានទៅរៀនសូត្រអ្វីទេ ដូចស្ត្រីខ្មែរជាច្រើនទៀតនៃជំនាន់របស់គាត់ដែរ ដូច្នេះមានតែស្មារតី ការចងចាំការចំណាំ នឹងមេរៀនជាមេគ្រួសារល្អដែលម្ដាយបានបង្រៀនតែប៉ុណ្ណោះ ដែលជាចំណេះសម្រាប់ប្រើក្នុងជីវិតមេគ្រួសាររបស់គាត់។ គឺនៅភ្នំពេញនោះឯង ដែលគាត់បានផ្តល់កំណើតឱ្យ "ចៅពិន" ដែលគាត់តែងរំលឹកជាញឹកញយឱ្យកូនចងចាំថា "ពេលម៉ែឈឺពោះកើតកូនឯង ប៉ាមិននៅទេ, ម៉ែបានហៅស៊ីក្លូជិះពីផ្ទះទៅ "ផ្សារកាប់គោ" សំដៅទៅពេទ្យធំ "ពេទ្យសម្ភពផះម៉ាម៉ាម" តែម្នាក់ឯងកាត់តាមមុខវាំង គឺជារាត្រីគេបញ្ចប់តាំងតុ (បុណ្យចំរើនព្រះជន្មសម្តេចសីហនុ) នៅមានមនុស្សខ្លះៗនៅឡើយ តែពន្លឺភ្លើងនៅព្រោងព្រៀតនៅឡើយ ម៉ាក់កើតកូនឯងនៅម៉ោង៣ទៀបភ្លឺ"...។ ពេលនោះគឺជាកំណើតនៃកូនទី៤នៃគ្រួសារលោក "អាត់សឺដង់" ម៉ាំង នាសម័យដែលប្រទេសនៅមិនទាន់បាត់រំជើបរំជួលពីសង្រ្គាមលោកលើកទី២នៅឡើយ ។ លោកស្រី ម៉ាំង ធ្លាប់បានបាននិយាយឱ្យកូនបងៗស្តាប់ពីការចងចាំគួរឱ្យរន្ធត់មួយទៀតនៃជីវិតស្ត្រីប្តីជាទាហ៊ានស្ដីពីជប៉ុនចាប់បារាំង **តទៅលេខក្រោយ**

*GLCC's members 20% OFF

# Reach the local Cambodian community with over 2K readers!

KhmerPost USA prints biweekly Cambodian-English newspaper, a 32-pages full color premium tabloid of 5,000 copies an issue that are free at 60+ locations in the Greater Lowell area. Schedule your 2017 advertising with us today!



## 2017 Print Dates

- January 6, 20 — July 7, 21
- February 3, 17 — August 4, 18
- March 10, 24 — September 8, 22
- April 7, 21 — October 6, 20
- May 5, 19 — November 3, 17
- June 9, 23 — December 8, 22

*All ads materials are due 3 days prior to printing date(s).

## Advertising Dimensions&Rates

| Ads Sizes | Specs (HxW) | Cost Per Issue | 3 Months 5% off | 6 Months 7.5% off | 12 Months 10% off |
|---|---|---|---|---|---|
| Full page | 13″x 10" | $460.00 | $2,622.00 | $5,106.00 | $9,936.00 |
| 4/8 page | 13″x5″ | $350.00 | $1,995.00 | $3,885.00 | $7,560.00 |
| 1/2 Page | 6.5″x10″ | $310.00 | $1,767.00 | $3,441.00 | $6,696.00 |
| 1/4 page | 6.5"x5" | $165.00 | $940.50 | $1,831.50 | $3,564.00 |
| 1/8 page | 3.25″x5″ | $90.00 | $513.00 | $999.00 | $1,944.00 |

- Ask us about the back page availability.

*Mention this ad and receive 20% off for 1/4 page and 1/2 page.

**Contact Soben Pin For Advertising Opportunities**

**Email: sobenpin@khmerpost.us**

**978-677-7163**

Office: **KhmerPost USA, LLC.** 45 Merrimack St. Suite 218A. Lowell, MA 01852

Hours: Monday – Friday. 9AM – 4PM

**Online at: http://khmerpost.us**

**SAVE-THE-DATE!**

**Our 10th Anniversary is on May 19th, 2017**